Formation, Dialogue, Cooperation

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែមិថុនា ឆ្នាំ២០១៧ លក់តម្លៃ ១០០០រៀល

លេខ ១០៣



## ឱសថបុរាណនៅតែមានគុណតម្លៃសម្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់ស្រទាប់វណ្ណៈ

ថតដោយ រិទ្ធី

Formation, Dailouge, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org

Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org

https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

ចាងហ្វាង : លោក លី សុវណ្ណា

សេចក្តីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# យុវជនកំពុងតែឲ្យតម្លៃទៅលើស្នាដៃសិល្បៈចម្រៀងមិនលួចចម្លងពីបរទេស

តែងនិពន្ធបទចម្រៀងថ្មីគឺជាចរន្តថ្មីមួយនៅក្នុងវិស័យសិល្បៈចម្រៀងនៅកម្ពុជានាសម័យបច្ចុប្បន្ននេះ ប៉ុន្តែទន្ទឹមនឹងការលើកទឹកចិត្តវាក៏ជាប្រធានបទថ្មីមួយដែលមានភាពចម្រូងចម្រាស់ រវាងអ្នកដែលខិតខំ និងអ្នកដែលចាំលួចចម្លងស្នាដៃគេដើម្បីប្រើប្រាស់ ឬធ្វើអាជីវកម្មបន្ត។

ដោយសារតែស្ថានភាពវាបែបនេះទៅហើយ ទើបការតែងនិពន្ធនេះ ត្រូវបានមហាជនមួយចំនួនបានសំដែងនូវការសារ-ទរផង ហើយក៏ស្ញាក់ស្ញើរផង ទោះបីជាមានការអន្តរាគមន៍ពីស្ថាប័នពាក់ព័ន្ធមួយចំនួនក៏ដោយ។

បច្ចុប្បន្ននេះយុវជនមួយចំនួន បានខិតខំប្រឹងប្រែង កសាងក៏ដូចជាការនិពន្ធថ្មីនូវបទចម្រៀង របស់ខ្លួនទៅតាមលទ្ធភាពដែលខ្លួនមាន ប៉ុន្តែក៏មានការរារាំងមួយចំនួន ក៏ដូចជា មូលហេតុមួយចំនួនដែលធ្វើឲ្យការនិពន្ធថ្មីនៅមានកម្រិត។

លោកម៉ក់ពិទូជាអ្នកនិពន្ធទំនុកភ្លេងនិងទំនុកចម្រៀង ស្នាដៃថ្មីដែលមិនចម្លងពីបរទេសមួយរូបបានថ្លែងថា ស្នារដៃរបស់លោក ត្រូវបានគាំទ្រដោយស្រទាប់មហាជនជាច្រើន ជាពិសេសយុវវ័យបច្ចុប្បន្ននេះ។

លោក បាននិយាយឲ្យដឹងថា ការតែងនិពន្ធគឺខួរក្បាលអារម្មណ៍ ជាមួយបេះដូងបូកបញ្ចូលគ្នាសរសេរចេញជារឿងអ្វីមួយដែល ផ្តោតសំខាន់ ហើយអ្វីដែលយើងសរសេរឲ្យអ្នកស្តាប់លោកបានយល់ ហើយមួយរយៈពេលចុងក្រោយនេះយើងឃើញមានការនិពន្ធថ្មីមានច្រើន មិនថាអ្នកនិពន្ធចាស់ អ្នកនិពន្ធថ្មី ទាំងក្មេងៗជំនាន់ឥឡូវ ។

លោកបានបន្តថា នៅក្នុងចំណោមអ្នកខំប្រឹងប្រែងទាំងនោះ គឺម្នាក់ៗបានខិតខំប្រឹងប្រែងមែនទែន ប៉ុន្តែស្នាដៃរបស់ពួកគាត់ ខ្លះក៏ទទួលបានជោគជ័យខ្លាំង ហើយអ្នកខ្លះក៏មិនទទួលជោគជ័យ ដែលនេះគឺជាចំណុចហានិភ័យមួយ។ លោកបានបញ្ជាក់ថា "ខ្ញុំសរសេរបទដំបូងក៏មិនមានអ្នកស្តាប់ដូចគ្នានោះដែរ គំនិតដំបូងរបស់យើងគឺវាក្មេងខ្ចីដូចគ្នា អ្វីដែលបានមកគឺបទពិសោធ និងខិតខំព្យាយាម"។

លោកបានបន្តថា ហេតុផលមានតែមួយគឺនៅពេលដែលយើងសរសេរអ្វីមួយទៅ គឺគេចាប់អារម្មណ៍ ហើយ សន្ទុះនៃការស្តាប់កាន់តែច្រើន នោះហើយជាភាពជោគជ័យរបស់យើង។ លោក ពិទូ បានធ្វើការរៀបរាប់បន្តថា អ្វីដែលជំរុញឲ្យលោកធ្វើការតែងនិពន្ធបទចម្រៀងថ្មី ដោយសារការស្រលាញ់របស់លោក។ លោកបានបន្តថា វិស័យសិល្បៈនេះ គឺលោកស្រលាញ់ខ្លាំងមែនទែនតាំងពីក្មេងមក។

ចំពោះឧបសគ្គវិញ លោក បានឲ្យដឹងថា ឧបសគ្គធំរបស់អ្នកនិពន្ធបទថ្មីគឺការចំណាយ សម្រាប់ចាយទៅលើកិច្ចការមួយចំនួនរាប់តាំងពីចំណុចទាក់ទងជាមួយឧបករណ៍ភ្លេង ស្ទូបយូ ពោលគឺមួយបទៗមិនតិចនោះឡើយ ហើយនឹងការងារទាក់ទាញចំណាប់អារម្មណ៍អ្នកគាំទ្រ។

ដើម្បីឲ្យការងារតែងនិពន្ធបទថ្មីនេះទទួលជោគជ័យ លោកបាន សំណូមពរទៅកាន់ភាគីដែលពាក់ព័ន្ធ ឲ្យអ្នកគាំទ្រ ទោះបីជាស្នាដៃតែងនិពន្ធល្អមិនល្អយ៉ាងម៉េចក៏ដោយ សូមកុំបង្អាប់ ហើយបង្វែរការបង្អាប់នោះ មកជាការជួយលើកទឹកចិត្តគ្នា។

លោកបានបញ្ជាក់ថា "គ្មានអ្នកណាគេធ្វើភ្លាមបានជោគជ័យភ្លាមនោះទេ ការបរាជ័យជាបទពិសោធន៍ ប៉ុន្តែសូមជួយលើកទឹកចិត្ត ហើយបើអាចក្រសួងពាក់ព័ន្ធគួរមានកម្មវិធីប្រឡង ពានអ្វីសម្រាប់ការតែងនិពន្ធនេះ"។

បច្ចុប្បន្នស្នាដៃបទច្រៀងថ្មីត្រូវបានអ្នកនិពន្ធវ័យក្មេងៗ និងអ្នកនិពន្ធរៀមច្បងបានធ្វើការផលិត ហើយទទួលបានការគាំទ្រជាបន្តបន្ទាប់ ដោយរួមទាំងសម្តេចតេជោ ហ៊ុន សែន ប្រមុខរដ្ឋាភិបាលកម្ពុជាផងដែរ។

លោករិន សុបញ្ញាសិទ្ធិ ជាយុវជនវ័យ ២២ ឆ្នាំមួយរូបបាននិយាយថា លោកតែងតែគាំទ្រជានិច្ចចំពោះស្នាដៃសិល្បៈថ្មីៗដែលយុវជននិងយុវនារីខ្មែរសម័យនេះបានបង្កើតឡើង។

លោកបានបន្តថា "វាជាមោទនភាពណាស់ដែលយើងអាចស្តាប់នូវបទភ្លេងនិងបទចម្រៀងថ្មីៗ ពីអ្នកនិពន្ធថ្មីៗជំនាន់ក្រោយរបស់យើង"។ លោកបានបន្តថា តាំងពីតូចមកដល់ពេលនេះ យើងស្តាប់តែបទភ្លេងពីបរទេស តែបានស្តាប់បទភ្លេងថ្មីៗដែលគេកែច្នៃ ដោយយកឧបករណ៍ភ្លេងបុរាណមកបញ្ចូលគ្នា ជាមួយនឹងឧប-ករណ៍សម័យមួយចំនួន គឺពិតជាពីរោះនិងប្លែកត្រចៀកគួរឲ្យគាំទ្រ ។

កញ្ញាចាន់ ចរិយា ជាយុវនិស្សិត មួយរូបបានថ្លែងថា កញ្ញានិងមិត្តភក្តិតែងតែលើកទឹកចិត្តនិងគាំទ្រនូវរាល់ស្នាដៃទាំងអស់ដែលជារបស់ខ្មែរជាពិសេស គឺសិល្បៈចម្រៀងនេះ ហើយមិនតែប៉ុណ្ណោះក៏បានថ្លែងជំរុញឲ្យ យុវជន និងយុវនារីគាំទ្រផលិតផលដែលជាស្នាដៃសិល្បៈរបស់ខ្មែរផងដែរ។

កញ្ញាបានបន្តថា តាំងពីសម័យសង្គមមុនមកដូចជា សម័យលោកតា ស៊ិន ស៊ីសាមុត អីគឺស្នាដៃចម្រៀងរបស់ខ្មែរគឺសុទ្ធតែជាស្នាដៃតែងនិពន្ធសុទ្ធៗ ប៉ុន្តែក្រោយមក គឺយើងដូចជាបាត់អត្តសញ្ញាណចម្រៀងរបស់យើងអស់ ដោយសារតែស្តាប់បទខ្មែរទៅ គឺអាចឮភ្លេងមកពីថៃ ពីចិន ពីកូរ៉េ ពីអាមេរិក ទើបតែ ប៉ុន្មានឆ្នាំនេះទេ ដែលយើងហាក់ដូចជាផុលផុស និងឲ្យតម្លៃទៅលើស្នាដៃតែងនិពន្ធដោយពលរដ្ឋខ្មែរ។

លោក កេត សុវណ្ណរិទ្ធ ជាប្រជាពលរដ្ឋកម្ពុជាមួយរូបបានថ្លែងថា បើស្តាប់តាមវិទ្យុតាមការប្រគុំតន្ត្រី ការចេញអាល់ប៊ុមចម្រៀងថ្មីៗនេះ បទដែលគេប្រកាសថា ជាស្នាដៃផ្ទាល់ខ្លួនមិនចម្លងពីបរទេស មានច្រើនដែរប៉ុន្តែ បើនិយាយអំពីភាគរយវិញនោះគឺវានៅតិចខ្លាំងណាស់ ដូច្នេះយើងទាំងអស់គ្នាគួរតែបន្តផ្តល់ការគាំទ្រ និងឲ្យតម្លៃដល់អ្នកដែលខិតខំបង្កើតការតាក់តែងស្នាដៃផ្ទាល់ខ្លួន ។

*ដោយ អរិយបុត្រ*



ថតដោយ លីហៀង

# ការសង្ស័យជារនាំងនៃភាពសុខដុមរមនា

ការសង្ស័យមិនទុកចិត្ត គឺជាធម្មជាតិតែងកើតមាននៅក្នុងមនុស្សគ្រប់រូប។ ការសង្ស័យគឺជាចម្ងល់ដែលតែងតែមានក្នុងជីវិតមនុស្ស។ ការដែលមានចម្ងល់ត្រូវតែមានចម្លើយ។ បើមានចម្លើយបានលុះត្រាអ្នកដែលឆ្ងល់ចេះស្វែងរកតាមរយៈការសួរនាំ ការស្រាវជ្រាវ ឬចូលក្នុងព្រឹត្តិការផ្ទាល់។ នោះវានាំឲ្យចម្រើនឡើង លើកាយវិញ្ញាណ និងគំនិតព្រមទាំងចំណេះដឹង។

ចំពោះការសង្ស័យមួយទៀត គឺការសង្ស័យមិនទុកចិត្តចំពោះបុគ្គលណាម្នាក់ដែលនៅជុំវិញខ្លួន នោះជាប្រការមួយគ្រោះថ្នាក់។ ព្រោះថាពេលណាម្នាក់មានការសង្ស័យចំពោះម្នាក់ទៀត ឬក្រុមមួយទៀត គេមិនអាចមើលឃើញចំណុចល្អនៃបុគ្គលនោះ ឬក្រុមនោះមាន និងកំពុងមាននោះទេ។ គេបានបិទចិត្តរួចទៅហើយ ព្រមទាំបានដៅនៃសញ្ញាអវិជ្ជមានរួចហើយ។ វាកាន់តែគ្រោះថ្នាក់ បើម្នាក់ណាមួយ ដែលសង្ស័យចំពោះបុគ្គលម្នាក់ ឬក្រុមមួយ ដោយបង្កើតពាក្យចចាមអារ៉ាម មួលបង្កាច់ លាបពណ៌បន្ថែមដើម្បីឲ្យស្ងប់គំនុំ និងបញ្ឆេះឲ្យមានចិត្តហិង្សាទៅម្នាក់ទៀត ឬក្រុមមួយទៀតនោះ។ ប្រការទាំងនេះ គឺកំពុងកើតមានក្នុងសង្គមកម្ពុជាសព្វថ្ងៃ។ នៅក្នុងព្រះសហគមន៍ក៏មានដែរ។

ការចោទប្រកាន់ ឬបង្កើតឲ្យមានពាក្យចចាមអារ៉ាម ដើម្បីបំផ្លាញបុគ្គលម្នាក់ទៀត ឬក្រុមមួយទៀតដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ក្រុមខ្លួន ជាចរិតអាក្រក់បំផុត។

រឿងនេះវាកើតឡើងព្រោះតែខ្វះការយល់ដឹង បិទចិត្ត បិទភ្នែក ស្អប់ ឬបិទដង្ហើមទាំងមានជីវិត។ ក្នុងគម្ពីរគ្រីស្តសាសនា ព្រះយេស៊ូសោយទិវង្គត ព្រោះតែការសង្ស័យ និងការច្រណែនឈ្នានីសនេះឯង។ គេចាប់ គេចោទ ទាំងព្រះយេស៊ូគ្មានកំហុស។

ពេលខ្លះក្នុងការរស់នៅរបស់យើងព្រោះតែការសង្ស័យនេះ អាចសម្លាប់មនុស្សដោយគ្មានការជំនុំជំរះ។

កម្ពុជាបានធ្លាប់ឆ្លងកាត់រួចហើយ ក្នុងរបបវាលពិឃាត ដែលដឹកនាំដោយក្រុមអាវខ្មៅប៉ុលពត។ មនុស្សជាច្រើនត្រូវសម្លាប់ ដោយការសង្ស័យ និងចោទប្រកាន់ដោយគ្មានហេតុផល ថាជាចារកម្មរបស់សហរដ្ឋអាមេរិក របស់សហភាពសូវៀត ជាមនុស្សរបស់វៀតណាម ជាអភិជន ជាជនក្បត់ជាតិ ក្បត់អង្គការព្រោះដំឡូងមួយដុំ ហូបឆ្ងាញ់មួយពេលជាដើម ឬមួយវិញទៀតគេយកមនុស្សទៅសម្លាប់ចោល ព្រោះតែការរាយការណ៍ផ្តេសផ្តាសរបស់បុគ្គលមួយចំនួន ឬបានមកពីចម្លើយដែលគ្មានមូលដ្ឋានជាដើម។

ចំណែកក្នុងគ្រួសារវិញប្តីប្រពន្ធដែលសង្ស័យគ្នានាំឲ្យគេលែងទុកចិត្តគ្នា គ្រួសារនឹងអន្តរាយ ក្នុងចិត្តម្នាក់ៗគ្មានសេចក្តីសុខនោះឡើយ។

សរុបមកវិញការសង្ស័យគ្នាទៅវិញទៅមក គឺមិនមែនជាប្រការល្អនោះឡើយ ការរាយការណ៍តាមពាក្យចចាមអារ៉ាម មួលបង្កាច់ មិនមែនជាទង្វើរល្អនោះដែរ។ ប្រការដែលល្អបំផុតបើមានការសង្ស័យបុគ្គលណា សូមស្គាល់បុគ្គលនោះ ជួបផ្ទាល់និយាយជាមួយគ្នា ដាក់បញ្ហាលើតុជជែក ដើម្បីស្វែងយល់ពីគ្នាទៅវិញទៅមក ដើម្បីភាពសុខដុមរមនា។

ធម៌របស់សន្តហ្វ្រង់ស៊ីស្កូ "ឱព្រះអម្ចាស់អើយ សូមព្រះអង្គប្រោសប្រណីឲ្យខ្ញុំចេះកសាងសន្តិភាពដែលមកពីព្រះអង្គ។ ពេលមនុស្សមានសង្ស័យ មិនទុកចិត្តគ្នា សូមព្រះអង្គឲ្យខ្ញុំចេះសម្រុះសម្រួលគេឲ្យទុកចិត្តគ្នាវិញ"។

# យុវជនយុវនារីចំនួន២០នាក់ ទទួលព្រះកាយព្រះគ្រីស្តលើកដំបូងនៅព្រះសហគមន៍សន្តយ៉ូសែប ផ្សារតូច

ក្រុមយុវជនយុវនារីចំនួន២០នាក់ក្នុងសម្លៀកបំពាក់អាវស និងស្លៀកសំពត់ពណ៌ទឹកប្រាក់ ព្រមទាំង៣នាក់ន្សែងផង ពួកគេបានទទួលព្រះកាយព្រះលោហិតលើកដំបូងនៃអគ្គសញ្ញាទទួលព្រះកាយព្រះគ្រីស្តនៅក្នុងពិធីថ្វាយអភិបូជាបុណ្យឱឡារិកព្រះកាយ និងព្រះលោហិតព្រះគ្រីស្តនៅព្រះសហគមន៍សន្តយ៉ូសែប ផ្សារតូច កាលពីថ្ងៃទី១៨ មិថុនា ២០១៧នេះ ក្រោមអធិបតីភាពលោកបូជាចារ្យរឿង ផ័ត្រសិរី ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍សន្តយ៉ូសែប ផ្សារតូចនៃមណ្ឌលសកម្មភាពភ្នំពេញខាងជើង របស់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។

ថ្លែងក្នុងពិធីថ្វាយអភិបូជានាឱកាសនោះលោកបូជាចារ្យរឿង ផ័ត្រសិរី បានមានប្រសាសន៍ថា នៅថ្ងៃនេះជាថ្ងៃបុណ្យយ៉ាងឱឡារិក ដែលយើងនាំគ្នាគោរពព្រះកាយព្រះលោហិតព្រះគ្រីស្ត គឺព្រះសហគមន៍ជួយរំកដល់គ្រីស្តបរិស័ទអំពីបុរេពនជីវិតពោលគឺមានអត្ថន័យមកពីព្រះកាយ និងព្រះលោហិតព្រះគ្រីស្តនេះ។ ជំនឿរបស់គ្រីស្តបរិស័ទកាតូលិក គឺមានជំនឿចំពោះព្រះកាយព្រះយេស៊ូ។ ពិធីបុណ្យនៅថ្ងៃនេះ គឺពិតជាមានអត្ថន័យ និងពិសេសមែនទែន គឺមានការគោរពព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ។

លោកបូជាចារ្យបន្ថែមថា ក្នុងពិធីនាថ្ងៃនេះមានយុវជនយុវនារីចំនួន២០នាក់ បានទទួលព្រះកាយព្រះលោហិតព្រះគ្រីស្តលើកដំបូងសម្រាប់ជីវិតរបស់ពួកគេ ដែលនេះជាថ្ងៃបុណ្យសំខាន់ និងជាឱកាសល្អមួយសម្រាប់ពួកគេដែរ ដោយសារព្រះយេស៊ូដែលមាននៅក្នុងព្រះកាយ ហើយមានព្រះជន្មគង់នៅជាមួយគ្រីស្តបរិស័ទ គឺបានបង្ហាញអំពីវត្តមានរបស់ព្រះអង្គនៅក្នុងលោកនេះ ។

លោកបូជាចារ្យរឿង ផ័ត្រសិរី បានបញ្ជាក់ថា ពិតមែននៅក្នុងជីវិតរបស់យើងម្នាក់ៗ នៅគ្រប់ទីកន្លែង គ្រប់ពេលវេលានាពេលសព្វថ្ងៃនេះ យើងមានរឿងរ៉ាវជាច្រើនរាប់មិនអស់ដែលនាំឲ្យយើងគិត ប៉ុន្តែសម្រាប់បងប្អូនគ្រីស្តបរិស័ទ យើងមានចំណុចសំខាន់មួយថា គ្រប់ទីកន្លែង គ្រប់ពេលវេលារបស់យើង គឺមានព្រះយេស៊ូនៅក្នុងជីវិតរបស់យើង ដោយសារតែខណៈពេលដែលយើងទទួលព្រះកាយ គឺមានព្រះនៅក្នុងជីវិតរបស់យើងហើយ។

ជាចុងក្រោយលោកបូជាចារ្យបានមានប្រសាសន៍ផ្តាំផ្ញើ ដល់យុវជនយុវនារីទាំងអស់ដែលបានទទួលព្រះកាយព្រះលោហិតព្រះគ្រីស្តក្នុងថ្ងៃនេះ សូមឲ្យបន្តដំណើរជីវិតរបស់ខ្លួន គឺរៀបចំខ្លួនឲ្យល្អក្នុងការទទួលព្រះយេស៊ូ និងទាំងអំឡុងពេលដើរតាមព្រះយេស៊ូ ដោយដឹងខ្លួនថា ព្រះជាម្ចាស់ គឺព្រះយេស៊ូ មិនដែលឃ្លាតឆ្ងាយពីជីវិតយើងឡើយ។

ក្នុងសម្លៀកបំពាក់ អាវស សំពត់ចងក្បិនពណ៌ទឹកប្រាក់ ប្អូនប្រុសវណ្ណ សុខហេង អាយុ១២ឆ្នាំ ជាអ្នកដែលបានទទួលអគ្គសញ្ញាទទួលព្រះកាយនិងព្រះលោហិតព្រះគ្រីស្តលើកដំបូង បានឲ្យដឹងថា នៅថ្ងៃនេះប្អូនបានទទួលព្រះកាយព្រះគ្រីស្តជាលើកដំបូង នាំឲ្យប្អូនសប្បាយចិត្តដែលប្រៀបបីដូចជាទទួលព្រះយេស៊ូនៅក្នុងជីវិត។ "ព្រះកាយព្រះយេស៊ូ ធ្វើឲ្យខ្ញុំពង្រឹងជំនឿ និងរស់នៅក្នុងជីវិតជាគ្រីស្តបរិស័ទ ដោយធ្វើឲ្យខ្ញុំមានកាន់ជំនឿកាន់តែរឹងមាំឡើង "។

ក្រោយពីបានទទួលព្រះកាយព្រះគ្រីស្តលើកដំបូងនៃជីវិតរបស់ខ្លួន ប្អូនស្រីទេវី អាយុ១៤ឆ្នាំ បានបង្ហាញនូវទឹកចិត្តសប្បាយរីករាយយ៉ាងក្រៃលែង ដែលប្អូនបានទទួលព្រះកាយនៅថ្ងៃនេះ។ ប្អូនស្រីបានបញ្ជាក់ថា ព្រះកាយព្រះគ្រីស្តពិតជាមានអត្ថន័យសំខាន់ខ្លាំងណាស់សម្រាប់ខ្ញុំ និងសម្រាប់ជំនឿរបស់ខ្ញុំ។

សូមបញ្ជាក់ថា នៅចុងក្រោយនៃការបញ្ចប់ពិធីថ្វាយអភិបូជានាព្រឹកនោះ ក៏មានការដង្ហែព្រះកាយព្រះគ្រីស្តចំនួនមួយជុំផងដែរ ព្រមទាំងមានការគោរព និងអធិដ្ឋានរួមគ្នានៅខាងមុខទីតម្កល់អដ្ឋិធាតុ។ បន្ទាប់ពីដង្ហែមួយជុំព្រះវិហាររួចមក លោកបូជាចារ្យនាំយកព្រះកាយព្រះគ្រីស្ត មកតម្កល់នៅព្រះវិហារធំខាងលើ ទុកសម្រាប់ឲ្យបងប្អូនគ្រីស្តបរិស័ទគោរព អធិដ្ឋាន និងនមស្ការព្រះកាយព្រះគ្រីស្តរហូតដល់ម៉ោង៣រសៀល នាថ្ងៃដដែល ៕

*ដោយ ឡុង សម្ផស្ស*



*ថតដោយ លីហៀង*

Messenger -103.indd 3 6/22/2017 5:27:01 PM

# ត្នោត និងការជួយសេដ្ឋកិច្ច ដែលមិនគួរមើលរំលង



ថតដោយ ផល សុផានិត

ប្រជាពលរដ្ឋខ្មែររាប់សិបនាក់នៅទូទាំងប្រទេសកំពុងបន្តរស់អាស្រ័យផល និងរកចំណូលពីទឹកត្នោត បើទោះបីជាខ្សត់អុសដុតរម្ងាស់ទឹកត្នោតជាបណ្តើរៗក្តី ប៉ុន្តែប្រជាពលរដ្ឋមួយចំនួន នៅតែបន្តរក្សានូវរបរឡើងត្នោតដើម្បីយកទឹកមករម្ងាស់ធ្វើជាស្ករត្នោត។

ចេះឡើងត្នោតតាំងពីវ័យកុមារ លោក ណាក់ ឌីណាល់ បានចេញពីស្រុកកំណើតនៅខេត្តកំពង់ចាម មកប្រកបរបរឡើងត្នោតនៅជាយទីក្រុងភ្នំពេញជាមួយភរិយាជាង៣ឆ្នាំមកហើយ។ បុរសវ័យ២៧ឆ្នាំ រូបនេះឡើងត្នោត ដើម្បីត្រងយកទឹករបស់វាទាំងជូរ និងផ្អែម យកទៅលក់ដើម្បីប្តូរយកប្រាក់។ ក្នុងបរិមាណទឹកត្នោត៥០លីត្រ គាត់អាចរកចំណូលបាន ៥ម៉ឺនរៀលក្នុងមួយថ្ងៃ។

លោក ណាក់ ឌីណាល់ បានថ្លែងថា គាត់បន្តអាជីពនេះ បន្តពីជីដូនជីតា ឪពុកម្តាយរបស់គាត់ តាំងពីគាត់បានកើតមក។ គាត់ឃើញតែគ្រួសាររបស់គាត់ធ្វើជីវិតលើដើមត្នោតនេះ ដែលជាមុខរបរដើងមិនដាប់ដី។ គាត់ពិបាករកដើមត្នោត ព្រោះនៅទីក្រុងភ្នំពេញ មិនសម្បូរដើមត្នោតនោះទេ ហើយគាត់ចេះតែជំនាញត្នោតនេះ។

លោក ដា ជាមេជាងម្នាក់នៅទីក្រុងភ្នំពេញ នៅតែជាប់ចិត្តនឹងរសជាតិផ្អែមឈ្ងុញរបស់ទឹកត្នោត។ គាត់ចូលចិត្តកាលពីក្មេង គឺរសជាតិផ្អែមរបស់វាធ្វើឲ្យគាត់មានកម្លាំង សុខភាពល្អ តែបើជូរគាត់ទទួលទានល្មមៗក៏អាចទទួលយកបានដូចគ្នា។

នៅក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល លោក ណែម លីន ប្រកបរបរឡើងត្នោត និងលក់ទឹកត្នោត អស់រយៈពេលរាប់ឆ្នាំមកហើយ។ បុរសវ័យ៤៨ឆ្នាំ បានរៀបរាប់ថា ក្នុងភូមិចម្ការដោ មានអ្នកឡើងត្នោតតែ២នាក់ប៉ុណ្ណោះ។

លោក ណែម លីន បានបន្តថា គាត់ឡើងយកទឹកត្នោតមកធ្វើស្ករ ដែលគាត់មានដើមត្នោត ៣០ដើម ដែលលោកឡើងមួយថ្ងៃទៅតាម តិចឬច្រើន តែបើគាត់ឡើងច្រើន បានផលក៏ច្រើនដែរ យ៉ាងតិច២០គីឡូក្រាមផងដែរ ដោយគិតជាទឹកប្រាក់ ក្នុង១គីឡូក្រាមតម្លៃពី៣០០០រៀល ទៅ៤០០០រៀល។

អ្នកជិតខាងរួមរបងជាមួយ លោក ណែម លីន ម្នាក់បានឈប់ប្រកបរបរឡើងត្នោត ហើយត្អូញត្អែរថា របរនេះចំណាយកម្លាំងច្រើន និងរកចំណូលបានតិច។

លោក ស៊ិន សល ហត់ណាស់ដែលម៉ោង ៤ ត្រូវឡើងទៅត្រងយកទឹករបស់វា នឹងយកទឹករបស់វាមករម្ងាស់ ពីម៉ោង៦ រហូតដល់ម៉ោង១១ទើបឆ្អិនអស់ នឹងជួនកាលដល់ម៉ោង១រសៀលបានឆ្អិនអស់ វាពិបាកក្នុងគ្រួសារខ្លាំងណាស់ និងណាមួយទំនិញវាថ្លៃទៀត ដែលយើងគិតទាំងបំពង់ ដែលចង់ស្មើដើមមិនអាចទៅរួច។

លោក ហួន ហ៊ីន មានស្រុកកំណើតក្នុងខេត្តកំពង់ស្ពឺ បានរស់អាស្រ័យដើមត្នោត បុរសម្នាក់នេះបានរៀបរាប់ថា ដើមត្នោតមានប្រយោជន៍ច្រើន ជាប្រភពចំណូលយ៉ាងសំខាន់ ជាច្រើនឆ្នាំមកហើយសម្រាប់អ្នកចម្ការដូចរូបគាត់។

លោក ហ៊ីន បានបន្តថា ត្នោតមានប្រយោជន៍ច្រើន ស្លឹកមកកាត់ដេរ ធ្វើជារោងផ្ទះ ធាងអាចធ្វើជាអុសដុតបាន ផ្លែយកមកធ្វើជាអាហារ និងជាចំណីសត្វអូសទាញ ដើមយកមកធ្វើផ្ទះ គ្រប់តួនៃដើមត្នោតមានប្រយោជន៍ ដែលលោករស់បាននឹងដើមត្នោតនេះ។

លោក ហ៊ីន បានបន្តថា អ្នកប្រកបរបរឡើងត្នោត ទាល់តែស្រលាញ់ដើមត្នោត អភិរក្សដើមត្នោត នៅពេលឃើញគេកាប់ យើងប្រាប់ពួកគេមិនឲ្យកាប់ដើមត្នោត ត្រូវថែរក្សា ដែលនិយាយឲ្យចំទៅ ជីវភាពពឹងផ្អែកលើដើមត្នោតនេះ។

លោក ហួន ហ៊ីន បានឲ្យដឹងទៀតថា គាត់មិនទាន់ធុញទ្រាន់ នឹងរបរឡើងត្នោតនេះទេ បើទោះបីជាអ្នកភូមិរោងដំរីខាងកើតភាគច្រើនបានបោះបង់មុខរបរនេះស្ទើរអស់ទៅហើយ។

លោក ហ៊ីន បានបន្តថា លោកអាចរកចំណូល បានប្រមាណជាជាង១០ម៉ឺនរៀលពីដើមត្នោត៣០ដើម។ អ្នកដែលបោះបង់ ដោយសារតែពួកគេមានមុខរបរផ្សេង ដោយប្រជាពលរដ្ឋខ្លះថា ថ្លៃទិញបង្គោងនោះវាថ្លៃ។ ឥលូវស្ករត្នោតមានទីផ្សារច្រើនជាងមុន ដែលបច្ចុប្បន្នមានអ្នកទិញដល់ផ្ទះតែម្តង គឺងាយស្រួលជាងមុន។

យោងតាមរបាយការណ៍របស់ខនហ្វើរ៉េល(Confirel) បានឲ្យដឹងថា ផុតពីរដូវវស្សាប្រជាកសិករមួយចំនួនបានសម្រាកពីការធ្វើស្រែ ពួកគេបានងាកមករកផលពីដើមត្នោត ពីព្រោះដើមត្នោតមានប្រយោជន៍ ដូចជា ស្លឹកត្នោតអាចយកទៅប្រក់ផ្ទះ និងអាចធ្វើជាស្នុកសម្រាប់ដាក់អីវ៉ាន់ ចំណែកទឹកត្នោតអាចផលិតជាស្រាទឹកត្នោត ទឹកខ្មេះ ហើយទឹកត្នោតក៏អាចផលិតជាស្ករត្នោត ដើម្បីរក្សាទុកឲ្យបានយូរ និងទៅតាមស្តង់ដា ដែលជាទូទៅយើងហៅថា ស្តង់ដារអន្តរជាតិ (International Standard) ឬមួយស្តង់ដារសេរីរាង្គ។ នៅក្នុងឆ្នាំ២០១៦ កម្ពុជាផលិតបានដល់១៥០តោន សម្រាប់ការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។

ប្រជាពលរដ្ឋមួយចំនួនដែលរស់នៅខេត្តកំពង់ស្ពឺ ជាខេត្តដែលសំបូរដើមត្នោតជាងគេនៅប្រទេសកម្ពុជា អាចទទួលផលពីដើមត្នោត មួយដើមប្រមាណជា ៨០ដុល្លាក្នុង១ឆ្នាំ។ តាំងពីឆ្នាំ២០០១ មកក្រុមហ៊ុនខនហ្វើរ៉េល (Confirel) បានជ្រើសរើសយកដើមត្នោតប្រមាណ៥៥០០ដើម ពីភូមិគោលដៅនៅខេត្តកំពង់ស្ពឺ ដើម្បីផលិតជាស្ករត្នោត ទឹកខ្មេះទឹកត្នោត ស្រាទឹកត្នោត ហើយនាំចេញយកទៅលក់នៅប្រទេសបារាំង កូរ៉េខាងត្បូង តៃវ៉ាន់ និងជប៉ុនជាដើម។

ត្នោត ជាដើមឈើមួយប្រភេទរបស់កម្ពុជា ដែលមានគុណប្រយោជន៍យ៉ាងច្រើនចាប់តាំងពី ឫស ដើម ធាង ស្លឹក ផ្កា ផ្លែ។ ក្រៅពីផ្លែខ្ចី យកមកធ្វើបង្អែមយ៉ាងឆ្ងាញ់ពិសា និងផ្លែទុំ យកមកធ្វើនំ អាកោត្នោតយ៉ាងឆ្ងាញ់ ទឹកត្នោតយកមកធ្វើជាភេសជ្ជៈផ្អែម ជូរ និងរម្ងាស់ធ្វើស្ករត្នោត ហើយឫសត្នោតអាចយកទៅធ្វើជាឱសថ ដោយយកមកដាំទឹកពិសាជួយកែអាការក្តៅក្នុង គ្រុនក្តៅ និងរលាកក្រពេញទឹកមាត់បាន។

អ្នកខ្លះប្រើជាថ្នាំប៉ូវកំលាំង ជួយបណ្តេញឈាម និងទម្លាក់ព្រូន ឬសត្វល្អិត ចេញស្អូច(Rebulla)លើកុមារ។ រីឯធាងត្នោត ប្រសិនបើធាងស្រស់ ត្រូវយកទៅអាំងភ្លើង ឬរោល ហើយពូតយកទឹកមកទទួលទានកែអាការរាករូស ឈឺស្លឹកស្រពន់។ ចំពោះស្លឹកត្នោត បើលីងឲ្យលឿង ហើយបុករហូតក្លាយទៅជាម្សៅម៉ត់ អាចជក់បាន។ បើតាមចាស់ៗគាត់ប្រាប់ថា អាចជួយកាត់បន្ថយសម្ពាធឈាម សម្រាប់អ្នកមានជំងឺលើសឈាម។

*ដោយ ផល សុផានិត*

Messenger -103.indd 4 6/22/2017 5:27:02 PM

# សាក់រូបកំពុងតែមាននិន្នាការពេញនិយមនៅក្នុងស្រទាប់យុវវ័យសម័យថ្មី



ថតដោយ សម្បត្តិ

ការសាក់រូបដែលពីមុនគេនិយមឃើញនៅក្នុងចំណោមបងៗ ពូៗ និងអ៊ុំៗ ក្នុងជួរយុទ្ធជន កាលពីអំឡុង សម័យសង្គ្រាមស៊ីវិលនោះ នៅពេលនេះស្រាប់តែកំពុងតែឃើញលេចឡើងនៅក្នុងស្រទាប់យុវវ័យសម័យថ្មី ជាពិសេសក្រុមដែលនិយមជីវិតបែបទាន់សម័យ។

លោកស្រី គង់ ដារី ម្ចាស់ហាងសាក់រូបមួយដែលមានឈ្មោះហៅថា បេសិក អាក បានថ្លែងថា ការសាក់រូបនេះឥឡូវកំពុងតែក្លាយជាសិល្បៈនៃការតុបតែងកាយពេញនិយមមួយនៅក្នុងស្រទាប់យុវវ័យដែលមានវ័យចន្លោះពីរង្វង់ ២០ឆ្នាំ រហូតដល់ ៣៦ ទៅ ៣៧ ឆ្នាំ ។ លោកស្រីបានបន្តថា ហាងលោកស្រីទើបតែចាប់ផ្តើមដំណើរការថ្មីៗនេះទេ ប៉ុន្តែយ៉ាងហោចណាស់នៅក្នុងមួយថ្ងៃមានអតិថិជនមករកសាក់រូបប្រហែលជា ២ទៅ ៣នាក់ដែរ។

លោកស្រីបានបញ្ជាក់ថា "ភាគច្រើននៃអតិថិជនខ្ញុំគឺ ក្មេងៗហើយមានទាំងស្រីទាំងប្រុស"។ តាមការអះអាងរបស់លោកស្រី ជាទូទៅការសាក់រូបនេះ គឺមានជារូបផ្កា សាក់ជាអក្សរខ្មែរ អក្សរអង់គ្លេស ចិន សាក់រូបនេះរូបនោះដោយតម្លៃវិញ គឺទៅតាមទំហំរូប ដែលអតិថិជនចង់បាន ដោយទាបបំផុតចាប់ពី ៥ដុល្លារឡើង ប៉ុន្តែការដែលនិយមនោះ គឺនៅក្នុងរង្វង់ប្រហែលជា១៥ ដុល្លារ។

លោកស្រីបានប្រាប់ឲ្យដឹងថែមទៀតថា សម័យមុនអ្នកដែលសាក់ ភាគច្រើនជាបងៗយុទ្ធជន ហើយរូបភាពសាក់នោះគឺជាយ័ន្តគាថា រូបមន្តដែលពួកគាត់ជឿថាអាចការពារខ្លួនគាត់បាន ប៉ុន្តែយុវវ័យសម័យនេះ គឺមិនមែនជាយ័ន្ត ទេ តែជាការបន្ថែមតម្លៃនិងភាពទាក់ទាញមួយ បន្ថែមពីលើគ្រឿងសំអាងជាម្សៅក្រែមទឹកអប់ ។

ជុំវិញការសាក់រូបនេះ លោក សេង ស័ក្តិ ជាអ្នកដែលកំពុងតែសាក់រូបមួយរូប ជាអក្សរថា ស័ក្តិ និងដាលីន បានឲ្យដឹងថា លោកបានសម្រេចចិត្តសាក់ជាអក្សរនេះគឺមានតម្លៃ១៥ដុល្លារ ហើយមូលហេតុដែលសាក់បែបនេះ គឺដើម្បីជាសាក្សីនៃក្តីស្រលាញ់រវាងរូបគេ និងគូដណ្តឹង។ លោកបានបន្តទៀតថា លោកបានសម្រេចចិត្តសាក់នេះ គឺមិនមានអ្នកណាមកបង្ខំ ឬប្រាប់ទេ ប៉ុន្តែឃើញមិត្តភក្តិគេសាក់ ដូចប្លែកក៏សាក់លេងបន្តិចនឹងគេ ដើម្បីទុកអួតគូដណ្តឹង។ លោកបានបន្តថា ការសាក់នេះគឺវាឈឺ ប៉ុន្តែដើម្បីបង្ហាញក្តីស្រលាញ់ក៏សុខចិត្ត។

លោកបានបញ្ជាក់ថា "មិនឲ្យឈឺម៉េចបើគេយកម្ជុលមកចាក់ទម្លុះស្បែក ប៉ុន្តែទ្រាំបន្តិចទៅ ដើម្បីប្លែក និងភាពភ្ញាក់ផ្អើលឲ្យនាង (គូដណ្តឹង)"។ លោកបានបន្តថា មិត្តភក្តិរបស់លោកភាគច្រើននិយមសាក់បែបនេះហើយពួកគេខ្លះសាក់ជារូបសត្វជារូបនេះរូបនោះច្រើន ។

លោក ងី សុខម៉េង ជាយុវជនវ័យ ២៥ ឆ្នាំមួយរូបដែលមានរូបសាក់ដៃ បានថ្លែងថា លោកបានសាក់រូបនេះមកប្រហែលជា ៣ឆ្នាំហើយ ដោយមូលហេតុនៃការសាក់នេះ ត្រូវបានលោកអះអាងថា គឺមិនមានអ្វីក្រៅពីធ្វើឲ្យប្លែកនោះទេ។

លោកបានបញ្ជាក់ថា "ដូចអត់មានអីផង គ្រាន់តែចង់សាក់ជារូបភាពលេង គ្រាន់បង្អួតមិត្ត"។ លោកបានបន្តទៀតថា នៅមុនពេលសាក់រូបនេះ នៅលើដៃ លោកចូលចិត្តបិទរូប ប៉ុន្តែក្រោយមកវាចេះតែចេញប្រឡាក់អាវ ហើយធុញនឹងបោកក៏សម្រេចចិត្តសាក់ទៅ។

លោកបានបន្តទៀតថា សម្រាប់លោកគឺសាក់នៅតែដៃស្រាលៗទេ ប៉ុន្តែសម្រាប់មិត្តភិក្តរបស់លោកខ្លះទៀត គឺសាក់ដល់ទៅខ្នងធំៗ ហើយអ្នកខ្លះទៀតសាក់នៅលើភ្លៅ ហើយមើលទៅដូចជា ប្លែក ហើយស្អាតម៉្យាង។

ជុំវិញការសាក់នេះ លោក ឈិត សុជាតិ ជាអ្នករត់ម៉ូតូឌុបមួយរូប និងជាអតីតយុទ្ធជនរំសាយមួយរូប ដែលមានស្នាមសាក់ពណ៌ខៀវព្រឿងៗនៅនឹងថ្ងាស មានលក្ខណៈជាអក្សរបុរាណ បានមានប្រសាសន៍ថា នេះជាយ័ន្តការពារខ្លួន ដែលលោកសាក់កាលពីកម្លោះពេលចូលទាហាន តាំងពីឆ្នាំ១៩៨០ ជាងមក។ លោកបានបន្តថា ក្រៅពីថ្ងាសនេះចេញ នៅលើខ្នង ក៏មានរូបសាក់នេះដែរ ប៉ុន្តែលោកបានអះអាងថា រូបសាក់នេះមិនមែនជារូបសាក់ដែលសាក់ដោយក្មេងៗ ឬស្រីៗនៅតាមកន្លែងកែសម្ផស្សណាមួយនោះទេ គឺស្នាមសាក់នេះ សាក់ដោយព្រះសង្ឃមួយអង្គនៅកំពង់ធំ ដែលពេលនេះ លោកសុគត់បាត់ហើយ។ លោកបានថ្លែងថា រូបសាក់នេះ គឺជាអាគមគាថា ដែលយើងជឿថាអាចជាយ័ន្តការពារ ។

លោកបានបញ្ជាក់ថា "គេមិនជឿ ខ្ញុំមិនដឹងថាម៉េចទេ ប៉ុន្តែសម្រាប់ខ្ញុំជឿ លើយ័ន្តនៅលើខ្នងនេះ។ នៅចាំអត់កាលវ៉ៃ ប៉ៃលិន ទាហានស្លាប់មិនតិចទេ តែខ្ញុំចេះតែសុខសប្បាយបានរស់រាន ស្គាល់សន្តិភាពនឹងគេដល់សព្វថ្ងៃនេះ។ ខ្ញុំជឿថា បើកុំតែមានយ័ន្តនេះ ខ្ញុំប្រហែលដូចជាគេដូចជាឯងដែលពលីចោលខ្មោចសម័យនោះនឹងគេបាត់ហើយ"។

ជុំវិញការសាក់របស់មនុស្សនៅសម័យបច្ចុប្បន្ននេះ លោកបានថ្លែងថា លោកក៏មិនដឹងដែរ ប៉ុន្តែឃើញថា យុវវ័យគេនិយមសាក់ច្រើន ហើយភាគច្រើន គឺពួកក្រុមយុវជនដែលនិយមលេងខ្លួន ពួកតារា ពួកកូនអ្នកធូធារ និងមានទាំងប្រុសទាំងស្រីតែម្តង។ លោកបានបន្តថា កាលសម័យលោក គឺគេសាក់ជារូបនាគ រូបខ្លា គ្រុឌ ហង្ស គាថា អក្សរបាលី ហើយគ្មានពណ៌គ្មានអីទេ គឺមានតែខ្មៅ ដែលបានមកពីការកម្លោចស្លឹកនេះស្លឹកនោះ យកផេះមកលាយប្រេងដូង ប្រេងចាន់ តាប៉ុណ្ណឹងវាពិសេសណាស់ហើយ ប៉ុន្តែឥឡូវ គឺប្លែកដែរ គេមានពណ៌ចម្រុះ ស្អាតៗថែមទៀតផង។

ជុំវិញរឿងសាក់នេះ លោកស្រី គង់ ដារី បានថ្លែងថា ជាការពិតនៅក្នុងចំណោមអតិថិជនដែលមករកសេវាកម្មសាក់រូបនៅហាងលោកស្រី គឺមានទាំងពីរភេទ ហើយពេលខ្លះក៏មានពួកភេទទីបីខ្លះដែរ ដោយខ្លះមករកសេវាកម្មសាក់នេះជារូបកាចសាហាវ ហើយនៅកន្លែងលាក់បាំងកៀនៗថែមទៀត ប៉ុន្តែហាងខ្ញុំអត់សាក់ទេពោល គឺយើងផ្តល់សេវាកម្ម ធម្មតាៗប៉ុណ្ណោះ។

លោកស្រីបានបន្តទៀតថា កន្លែងដែលហាងលោកស្រីអាចផ្តល់សេវាកម្មជូនដល់អតិថិជននោះ គឺត្រឹមសេវាកម្មសាក់ដៃ ខ្នង ស្មា កញ្ចឹងក កជើង ចង្កេះ បរបូមាត់ ចិញ្ចើម ពោលគឺកន្លែងសាមញ្ញតែប៉ុណ្ណោះ។

*ដោយ អរិយបុត្រ*

# ចិញ្ចើមផ្លូវ ទីកន្លែងដែលពលរដ្ឋក្រីក្ររាប់សិបពាន់នាក់កំពុងតែរកប្រាក់ចំណូល

តាមបណ្តាចិញ្ចើមផ្លូវនានា នៅតាមទីប្រជុំជននានាទាំងនៅទីក្រុងភ្នំពេញ និងនៅទីប្រជុំជននានា គឺជាកន្លែងដែលប្រជាពលរដ្ឋរាប់សិបនាក់កំពុងតែប្រកបរបរចិញ្ចឹមជីវិត ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយអាជ្ញាធរគួរតែរៀបចំសណ្តាប់ធ្នាប់ ។

កុមារី លក្ខិ មានអាយុ ១៤ឆ្នាំ ជាអ្នកលក់ត្រី នៅតាមចិញ្ចើមផ្លូវមួយកន្លែងនៅផ្សារព្រែកឯងបានឲ្យដឹងថា ត្រី ខ្យង អន្ទង់ សត្វទា ជារបរដែលប្អូនស្រីកំពុងលក់ដូរ ។

ស្រី លក្ខិ បានបន្តថា ជាមួយនឹងមុខរបរតាមចិញ្ចើមផ្លូវបន្តិចបន្តួចនេះ គឺអាចផ្តល់ប្រាក់ចំណូល ប្រមាណជាជាង ១៦០.០០០រៀល ដែរនៅក្នុងមួយថ្ងៃៗ ដើម្បីចិញ្ចឹមគ្រួសារ ។

លោកស្រី ស្រី ភក្តី ជាអ្នកលក់មាន់ និងទាអាំង តាមចិញ្ចើមផ្លូវមួយរូបទៀតវិញបានរៀបរាប់ថា របរតាមចិញ្ចើមផ្លូវនេះ គឺមានអាយុកាលជាង២០ឆ្នាំមកហើយ ដោយកាលពីលក់ដំបូងមានតែម្នាក់ទៅពីរនាក់ប៉ុណ្ណោះ ឥឡូវមានច្រើន ប៉ុន្តែម្នាក់ៗអាចរកចំណូលគ្រាន់តែចិញ្ចឹមគ្រួសាររៀងៗខ្លួន ។

លោកស្រី ភក្តី បានថ្លែងថា លោកស្រីចង់បន្តលក់នៅតាមចិញ្ចើមផ្លូវនេះតទៅទៀតដោយសារតែ វាងាយស្រួលសម្រាប់អតិថិជន ។

លោកស្រីបានបញ្ជាក់ថា "បើទោះបីជាខាងអាជ្ញាធរបានរៀបចំផ្សារថ្មីក៏ដោយ ក៏ខ្ញុំនៅតែបន្តលក់នៅតាមដងផ្លូវនេះបន្តទៀត មូលហេតុដោយសារតែអតិថិជនភាគច្រើន លោកពិបាកក្នុងការធ្វើដំណើរឆ្ងាយពីកន្លែងទុកដាក់រថយន្ត និងណាមួយខ្លាចបាត់បង់អតិថិជនដែលធ្លាប់ស្គាល់" ។

អាជីវករដែលជាអ្នកលក់ដូរ មីគោកមួយរូបគឺ លោក ចិន សៅហេង បានរៀបរាប់ថា លោកធ្វើការលក់ដូរនៅតាមចិញ្ចើមផ្លូវនេះអស់រយៈពេលជាង១០ឆ្នាំមកហើយ ។ លោកបានបន្តថា ជាង១០ឆ្នាំនេះ ចិញ្ចើមផ្លូវគឺជាកន្លែងរកទទួលទានរបស់លោក ។

លោកបានបញ្ជាក់ថា "ចិញ្ចើមផ្លូវជាកន្លែងខ្ញុំរកស៊ីតាំងពីម៉ោង៦ព្រឹក ដល់ម៉ោង ៧ល្ងាច ដោយក្នុងមួយថ្ងៃខ្ញុំអាចរកចំណូលបានពី ២០០.០០០រៀល ទៅ ២៥០.០០០រៀលដែរ" ។

លោកហេង បានបន្តថា អតិថិជន របស់លោកភាគច្រើនជាអ្នកដំណើរ ដែលធ្វើដំណើរតាមដងផ្លូវ និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ។

ងាកមកមើល នារីម្នាក់ដែលកំពុងញាប់ដៃ បុកល្ហុង សម្រាប់អតិថិជនរបស់គាត់ អ្នកនាង ស្រី បានរៀបរាប់ថា គាត់ធ្វើការលក់នៅទីនេះអស់រយៈពេលជាង ៥ឆ្នាំមកហើយ ដែលក្រោយពីគាត់មានគ្រួសារហើយត្រូវបានឪពុកម្តាយ ចែកតូបធ្វើការលក់ដូរចិញ្ចឹមជីវិត ។ អ្នកបុកល្ហុងរូបស្រស់ម្នាក់នេះ បានបន្តថា រសជាតិបុកល្ហុង មានពីររសជាតិ ដែលបុកដាក់កាពិ តាមបែបថៃ និងរសជាតិធម្មតា ។

គាត់បានបញ្ជាក់ទៀតថា ក្នុងមួយត្បាល់ខ្ញុំរកចំណូលបាន ៦០០០រៀល គ្រាន់នឹងរស់ ។ គាត់ក៏បានបន្ថែមទៀតថា សព្វថ្ងៃនេះរបរលក់ដូរតាមចិញ្ចើមផ្លូវនេះមានច្រើនកន្លែងដែរ ។

លោក កុសល ជាអាជីវករលក់គុយទាវទូក តាមចិញ្ចើមផ្លូវមួយរូបបានថ្លែងថា ចិញ្ចើមផ្លូវក៏ជាកន្លែងដែលគាត់មានកំណើតរហូតមកដល់ពេលនេះ ។

គាត់បានរៀបរាប់ថា គាត់ពីមុនធ្លាប់ជាចុងភៅនៅភោជនីយដ្ឋានមួយរូប ប៉ុន្តែកាលពី ៦ឆ្នាំមុន ។ គាត់បានបែកគំនិតមកប្រកបរបរជាអ្នកលក់គុយទាវទូកតាមចិញ្ចើមផ្លូវនេះដោយខ្លួនលោកវិញ ។

គាត់បានបញ្ជាក់ថា "យើងធ្លាប់ឮរសជាតិគុយទាវទូកនេះ នៅកណ្តាលភ្នំពេញទេ ប៉ុន្តែពេលនេះនៅតាមចិញ្ចើមផ្លូវនៅជាយរាជធានីក៏មានលក់នេះដែរ ។

លោកកុសល បានបន្តទៀតថា គាត់បានចាប់អាជីពនេះ វាងាយស្រួល ពោលគឺជិតភូមិដ្ឋានរបស់គាត់ផ្ទាល់តែម្តង ។

អ្នកលក់គុយទាវរូបនេះ បានបន្តថា គុយទាវនេះមានតម្លៃថ្លៃជាងគុយទាវធម្មតាដោយសារតែ មានគ្រឿងផ្សំច្រើនមុខ និងជាពិសេសរសជាតិមុតជាប់ចិត្តអតិថិជន ។ គាត់លក់នៅទីនេះចាប់ពីម៉ោង ៧ព្រឹក រហូតដល់ម៉ោង ៨ល្ងាច មុខរបរនេះបានជួយឲ្យជីវភាពរបស់គ្រួសារគាត់មានជីវភាពល្អ ដោយសារតែលោកមិនតម្រូវឲ្យជួលទីតាំងសម្រាប់លក់នោះទេ ។

ការលក់ដូរនៅតាមផ្លូវបែបនេះគឺ ពិតជាបានរួមចំណែកបង្កលក្ខណៈងាយស្រួល ម្យ៉ាងសម្រាប់អ្នកដែលមានជីវភាពទាប និងមធ្យមដែលត្រូវការនូវរបស់ទាំងនេះទទួលទានជាប្រចាំថ្ងៃ និងម្យ៉ាងទៀតវារួមចំណែកក្នុងការកាត់បន្ថយគម្លាតនៃផ្លូវធ្វើដំណើរ និងការស្វែងរកទិញវា ។ ម្យ៉ាងវិញទៀតការលក់ដូរនៅលើចិញ្ចើមផ្លូវ គឺជាកន្លែងជួយបង្កើតមុខរបរ និងការងារដល់ប្រជាពលរដ្ឋ ហើយវាក៏បានរួមចំណែកឲ្យប្រជាពលរដ្ឋ ជាអាជីវករមួយចំនួនមានភាពធូរធារផងដែរ ប៉ុន្តែទន្ទឹមនឹងនោះវាក៏មានផលអវិជ្ជមានដល់សណ្តាប់ធ្នាប់សារណៈពោលគឺ ការកកស្ទះចរាចរណ៍ និងបង្កផលប៉ះពាល់ដល់បរិស្ថាន ហើយភាគច្រើនពុំសូវមានស្តង់ដារអនាម័យល្អគ្រប់គ្រាន់ ។

លោក សូនិត ជាអ្នកដំណើរមួយរូបបានថ្លែងថា សម្រាប់គាត់ការលក់ដូរតាមផ្លូវបែបនេះវាពិតជាល្អដែរ ដែលអាចឲ្យគាត់ជ្រើសរើសក្នុងតម្លៃសមរម្យជាងនៅទីផ្សារដែលអាជ្ញាធររៀបចំ ។

អ្នកស្រី សាមឌី ជាប្រជាពលរដ្ឋមួយរូបបានមានប្រសាសន៍ថា ការលក់ដូរតាមផ្លូវបែបនេះ វាងាយស្រួលសម្រាប់គាត់ និងប្រជាពលរដ្ឋឯទៀតៗ ប៉ុន្តែវាក៏មានផលអវិជ្ជមានដែរ ដោយសារតែបង្កការកកស្ទះចរាចរណ៍ នៅពេលដែលអ្នកទិញឈប់រថយន្ត ដើម្បីបញ្ជាទិញនូវនំចំណីទាំងអស់នេះ ម្យ៉ាងវាអាចនិងបាត់បង់សោភណ្ឌភាពទីក្រុងផងដែរ ។

លោក ជិន សុជាតិ ជាប្រជាពលរដ្ឋមួយរូបទៀតបានថ្លែងថា យើងក៏ត្រូវការរស់ គេក៏ត្រូវការរស់ ដូច្នេះការហាមឃាត់គេមិនឲ្យលក់តាមចិញ្ចើមផ្លូវដោយសារតែវាកកស្ទះ ដោយសារតែគ្មានសណ្តាប់ធ្នាប់ដូចដែលអាជ្ញាធរធ្លាប់ប៉ុនប៉ងរៀបចំនោះគឺពិបាក ប៉ុន្តែប្រសិនបើយើងណែនាំ អប់រំរឿងអនាម័យបរិស្ថាន សណ្តាប់ធ្នាប់ និងឲ្យមានរបៀបរៀបរយ គឺប្រហែលជាប្រសើរ ។

លោកបានបន្តថា នៅស្រុកណាក៏ដូចជាស្រុកណាដែរ មើលតែនៅថៃ នៅវៀតណាម គឺមានដូចតែគ្នាទេ ប៉ុន្តែគេមានរបៀបរៀបរយគេល្អណាស់ ចរាចរណ៍ក៏មានស្ទះ អ្នកដំណើរនៅតែមានផ្លូវដើរ អ្នកលក់នៅតែមានកន្លែងលក់ រីឯអ្នកទិញក៏មានកន្លែងទិញ ពោលគឺស្រួលទាំងអស់គ្នា ។

*ដោយ អរិយបុត្រ*



ផ្សារចិញ្ចើមផ្លូវ នៅព្រែកបារ ថតដោយ រិទ្ធី

# ស៊ីក្លូជាមធ្យោបាយធ្វើដំណើរដែលពលរដ្ឋសឹងតែបំភ្លេចចោល



ថតដោយ ផល សុផានិត

*នៅកម្ពុជានាពេលបច្ចុប្បន្នសេវាកម្មដឹកជញ្ជូនត្រូវបានគេអះអាងថាបានរីកចម្រើនជាបន្តបន្ទាប់ ឈានទៅដូចបណ្តាប្រទេសនានានៅក្នុងតំបន់ ប៉ុន្តែមានមធ្យោបាយធ្វើដំណើរមួយដែលកំពុងតែ ឈានទៅបាត់បង់គឺស៊ីក្លូ។ ដើម្បីជ្រាបអំពីស្ថានភាពនៃមធ្យោបាយដឹកជញ្ជូនមួយនេះ **អ្នកនាំសារ** សូមអនុញ្ញាតណែនាំមិត្តអ្នកអានឲ្យជួបជាមួយនឹង លោក **អ៊ឹម សម្បត្តិ** ជានាយកសមាគមស៊ីក្លូ ។*

**អ្នកនាំសារ៖** តើលោកនាយកអាចជម្រាបបានទេថាអ្វីទៅជាស៊ីក្លូ ហើយស៊ីក្លូត្រូវបានកើតឡើងក្នុងឆ្នាំណា និងមកទល់បច្ចុប្បន្ននេះ តើមានចំនួនស៊ីក្លូសរុបចំនួនប៉ុន្មាន ដែលនៅសល់?

**លោកអ៊ឹម សម្បត្តិ៖** ស៊ីក្លូត្រូវបានគេដឹងថា ជានិមិត្តរូបនៃសេវាដឹកជញ្ជូនមួយនៅក្នុងរាជធានីភ្នំពេញ ប៉ុន្តែវាកំពុងតែប្រឈម នឹងការបាត់បង់នៅក្នុងពេលអនាគត ដូច្នេះបើអ្នកទេសចរមិនចង់បាត់បង់ស៊ីក្លូ គេអាចរួមចំណែកអភិរក្សស៊ីក្លូ។ ស៊ីក្លូត្រូវបានគេដឹងថាវាមានកំណើតកើតឡើងក្នុងសង្គមកម្ពុជាកាលពីឆ្នាំ ១៩៣៦ ក្នុងសម័យអាណានិគមបារាំង។ បច្ចុប្បន្ននេះការនិយមប្រើប្រាស់ស៊ីក្លូជាមធ្យោបាយដឹកជញ្ជូននោះកំពុងតែត្រូវបានថយចុះ។ កាលពីទស្សវត្សរ៍នៃឆ្នាំ១៩៩០ ស៊ីក្លូមានចំនួនប្រមាណជាជាង ៦.០០០ ឥឡូវនេះបានធ្លាក់ចុះមកនៅត្រឹមតែជាង៤០០ស៊ីក្លូ។

**អ្នកនាំសារ៖** តើលោកនាយកអាចបញ្ជាក់បានទេ ថាមូលហេតុអ្វីបានជាចំនួនស៊ីក្លូ ក្នុងរាជធានីភ្នំពេញ មានការថយចុះយ៉ាងច្រើនបែបនេះ?

**លោកអ៊ឹម សម្បត្តិ៖** បច្ចុប្បន្ននេះប្រជាពលរដ្ឋកម្ពុជាគឺ លែងមានការគាំទ្រក្នុងការជិះស៊ីក្លូដូចពីមុន ទៀតហើយ ដោយសារតែ ស៊ីក្លូដឹកអីវ៉ាន់បានចំនួនតិច បើកបរយឺតមិនទាន់សភាពការណ៍ជាដើម។ ហើយម្យ៉ាងទៀតនៅរាជធានី ក៏មានការកើនឡើងនូវចំនួន មធ្យោបាយដឹកជញ្ជូនទំនើប កាន់តែច្រើនហើយ មានតម្លៃសមរម្យជាងការប្រើប្រាស់ស៊ីក្លូ ដូច្នេះហើយបានជាមធ្យោបាយដឹកជញ្ជូនមួយនេះ ប្រឈមនឹងការបាត់បង់នៅពេលអនាគត។

**អ្នកនាំសារ៖** សូមលោកនាយកអាចបញ្ជាក់បន្តិចថា តើស៊ីក្លូប្រឈមនឹងភាពលំបាកដូចម្តេចខ្លះ ហើយភាគច្រើនអ្នកប្រកបរបរនេះ មានវ័យប៉ុន្មាន ហើយតើមូលហេតុអ្វីបានជាពួកគាត់ប្រកបរបរនេះ បើទោះបីជាមានភាពលំបាកបែបនេះ?

**លោកអ៊ឹម សម្បត្តិ៖** ការងារជាក់ស៊ីក្លូមានភាពលំបាកច្រើន ពោលគឺជាមធ្យោបាយដឹកជញ្ជូន ដែលប្រើដោយកម្លាំងកាយ ណាមួយពួកគាត់ភាគច្រើនសុទ្ធតែចាស់ៗទៀត ប៉ុន្តែអ្វីដែលគួរឲ្យសរសើរគាត់នោះគឺ ពួកគាត់ប្រកបរបរមួយនេះដោយសុចរិត គាត់ប្រឹងប្រែងពីកម្លាំងកាយ កម្លាំងចិត្តរបស់គាត់ ប្រកបរបរនេះដើម្បីជីវភាពខ្លួនឯង និងផ្គត់ផ្គង់ទៅគ្រួសារគាត់នៅស្រុកកំណើត។

**អ្នកនាំសារ៖** តើកាលពីថ្ងៃទី០៦ ខែមិថុនា សមាគមរៀបចំកម្មវិធីអ្វី ?

**លោកអ៊ឹម សម្បត្តិ៖** ថ្ងៃនោះយើងដឹងថាមានប្អូនៗនិស្សិត ស្ម័គ្រចិត្តធ្វើកម្មវិធីនេះឡើងដើម្បី ប្រមូលពូៗស៊ីក្លូទាំងនេះផ្តល់ជាអំណោយ។ អំណោយទាំងនេះមិនគ្រប់គ្រាន់នោះទេតែអាចជួយជីវភាពពួកគាត់បានមួយរយៈពេលផងដែរ។ ទោះបីជាការប្រមូលផ្តុំគ្នានេះតិចតួចក៏ដោយ តែវាបង្ហាញពីការចូលរួមរបស់យុវជនក្នុងសង្គមជាតិយើង ។

**អ្នកនាំសារ៖** តើនៅក្នុងពេលសព្វថ្ងៃនេះ តើនរណាជាអ្នកនៅប្រើប្រាស់មធ្យោបាយដឹកជញ្ជូនបុរាណមួយនេះបន្ត?

**លោកអ៊ឹម សម្បត្តិ៖** ដូចដែលរៀបរាប់ខាងលើហើយរបរជាក់ស៊ីក្លូ គឺសឹងតែបាត់បង់ ដោយសារតែប្រជាពលរដ្ឋតិចតួចប៉ុណ្ណោះដែលនៅប្រើប្រាស់ និយាយរួមទៅ គឺជិះស៊ីក្លូ គឺសឹងតែអត់ ប៉ុន្តែយើងអាចទទួលភ្ញៀវទេសចរបរទេសខ្លះ ដែលពួកគេចាប់អារម្មណ៍ចង់ជិះកំសាន្តនៅក្នុងរាជធានីភ្នំពេញ។

**អ្នកនាំសារ៖** តើលោកយល់ថា សង្គមខ្មែរគួរតែអភិរក្សមធ្យោបាយដឹកជញ្ជូនមួយប្រភេទនេះដែរឬទេ?

**លោកអ៊ឹម សម្បត្តិ៖** ជាការពិតបើម្នាក់ៗមិនមានអ្នកណារវល់និងឲ្យតម្លៃ ស៊ីក្លូនឹងបាត់បង់នៅថ្ងៃអនាគត ដូច្នេះចូរចូលរួមផ្តល់ការគាំទ្រដល់ស៊ីក្លូ ដើម្បីអាចឲ្យមុខរបរនេះ អាចបន្តវត្តមាននៅក្នុងរាជធានីដើម្បីទុកជាសម្បត្តិវប្បធម៌មួយសម្រាប់សង្គមជាតិ។

**អ្នកនាំសារ៖** ជាចុងក្រោយតើលោកនាយកមានអ្វីផ្តាំផ្ញើទៅប្រជាពលរដ្ឋ អំពីស៊ីក្លូនេះដែរឬទេ ?

**លោកអ៊ឹម សម្បត្តិ៖** ជាចុងបញ្ចប់ខ្ញុំសូមផ្តាំដល់ពលរដ្ឋថា អ្នកប្រកបរបរស៊ីក្លូនេះភាគច្រើនជាមនុស្សមានវ័យចំណាស់ ដែលពួកគាត់ត្រូវការជំនួយ និងការគាំទ្រលើកទឹកចិត្តជាច្រើនពីសប្បុរសជននានា។ សកម្មភាព និងការចូលរួមចំណែកគាំទ្រស៊ីក្លូមួយចំនួនរបស់បងប្អូន គឺអាចនឹងជួយលើកទឹកចិត្តពួកគាត់ ក្នុងការតស៊ូប្រឹងប្រែងក្នុងជីវិត ជាពិសេសក្នុងការបន្តការគាំពារមុខរបរនេះឲ្យបន្តស្ថិតស្ថេរនៅរាជធានីភ្នំពេញ។

*ដោយ អរិយបុត្រ និងផានិត*

## មធ្យោបាយដឹកជញ្ជូននៅរាជធានីភ្នំពេញសព្វថ្ងៃ

នៅរាជធានីភ្នំពេញដែលជាមជ្ឈមណ្ឌលនយោបាយ ពាណិជ្ជកម្ម វប្បធម៌ និងប្រវត្តិសាស្ត្ររបស់ប្រទេស គឺមធ្យោបាយដឹកជញ្ជូនមានសឹងតែគ្រប់យ៉ាង តាំងពីទោចក្រយានយន្ត រថយន្ត ខណៈដែលមធ្យោបាយសម្រាប់ ផ្តល់សេវាកម្មធ្វើដំណើរ គឺមានច្រើនផងដែរ។

ម៉ូតូកង់បី ដែលអ្នកខ្លះហៅថា "ម៉ូតូ សណ្តោងរ៉ឺម៉ក" ហើយអ្នកខ្លះហៅថា ( ទុកទុក ) ជាមធ្យោបាយ ដែលមានការពេញនិយមច្រើននៅភ្នំពេញ។ មធ្យោបាយនេះ ច្រើនប្រមូលផ្តុំនៅតំបន់ទេសចរណ៍ពេញនិយមដូចជា នៅមាត់ទន្លេ និងនៅតាមសណ្ឋាគារទេសចរណ៍នានា។

ម៉ូតូឌុប ជាមធ្យោបាយដឹកជញ្ជូនមួយដែលមានគ្រប់ទីកន្លែង។ វាគឺជាមធ្យោបាយធ្វើដំណើរសាធារណៈដ៏សាមញ្ញ និងលឿនរហ័សជាងគេ។

រថយន្តតាក់ស៊ីសាធារណៈ បច្ចុប្បន្ននេះកំពុងតែរីកដុះដាលជាបន្តបន្ទាប់តាំងពីក្រុមហ៊ុន រហូតដល់មានបុគ្គលខ្លះចាប់ផ្តើមផ្តល់សេវាកម្មដឹកជញ្ជូននេះដែរ។ សេវាកម្មដឹកជញ្ជូនតាមតាក់ស៊ីនេះ គឺអាចឃើញមានរង់ចាំ នៅក្រៅសណ្ឋាគារធំៗ។

រថយន្តតាក់ស៊ីម៉ែត្រវិញគឺកំពុងតែរីកដុះដាលខ្លាំង ហើយកំពុងតែទទួលការពេញនិយម នៅក្នុងការធ្វើដំណើររបស់អ្នកទេសចរបរទេស និងប្រជាពលរដ្ឋទូទៅ។ វាមានភាពងាយស្រួលផាសុខភាព ដោយគិតលុយទៅតាមគីឡូ និងនាទីកំណត់។

ស៊ីក្លូ ជាមធ្យោបាយដឹកជញ្ជូនប្រើដោយកម្លាំងបែបប្រពៃណីមួយ សម្រាប់រាជធានីភ្នំពេញ ប៉ុន្តែវាកំពុងតែប្រឈមមុខនឹងការបាត់បង់ ដោយគេឃើញមានការនិយមជិះតែពីសំណាក់ភ្ញៀវទេសចរបន្តិចបន្តួចប៉ុណ្ណោះ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មធ្យោបាយដឹកជញ្ជូននេះនៅមាននៅឡើយនៅក្នុងរាជធានី ។

រថយន្តក្រុង កំពុងតែត្រូវបានពង្រីកនិងពង្រឹងសេវាកម្មបន្ថែមសម្រាប់ជួយសម្រួលនៅក្នុងការផ្តល់សេវាកម្មដឹកជញ្ជូននៅក្នុងរាជធានីភ្នំពេញ។ នៅពេលបច្ចុប្បន្ននេះវាមានខ្សែរត់ កាត់មហាវិថីធំៗមួយចំនួន ប៉ុន្តែសាលារាជធានីកំពុងតែរៀបចំពង្រីកសេវាកម្មនេះថែមទៀត ។

ចំពោះកាណូតវិញគឺមាន ប៉ុន្តែវាមិនទាន់ក្លាយជាមធ្យោបាយដឹកជញ្ជូនសាធារណនៅឡើយទេ។ សេវាកម្មកាណូតដែលមានគឺសម្រាប់អ្នកដែលមានលុយជួលជិះកំសាន្តតាមដងទន្លេ ប៉ុន្តែនៅពេលអនាគតប្រហែលជាមាន ពីព្រោះក្រសួងសាធារណការនិងដឹកជញ្ជូនកំពុងតែរៀបចំសិក្សាអំពីការដាក់វាឲ្យទៅជាសេវាដឹកជញ្ជូនសាធារណៈ។



ថតដោយ ផល សុផានិត

# ជាស្ត្រីកំដរភ្ញៀវ មានការលំបាកខុសពីកិច្ចការរបស់នារីដទៃទៀត




ស្ថិតនៅក្រោមពន្លឺភ្លើងពណ៌ ផ្ទៃមុខលម្អរបន្ថែមដោយក្រែមម្សៅយ៉ាងស្រស់ផូរផង់រួមទាំងឈុតសំលៀកបំពាក់បង្ហាញនូវភាពសិចស៊ីដ៏ជាទីពេញភ្នែកពីសំណាក់បុរសៗ កញ្ញា សុភស្ត និងមិត្តនារីដទៃទៀត កំពុងតែអង្គុយតម្រៀបគ្នាជាជួរនៅពីមុខហាងខារ៉ាអូខេដើម្បីរង់ចាំភ្ញៀវមកជ្រើសរើស យកទៅអង្គុយកំដរច្រៀងរាំផឹកស៊ីយ៉ាងសប្បាយក្អាកក្អាយ។

ជានារីកំដរភ្ញៀវច្រៀងរាំផឹកស៊ី គឺត្រូវផ្តល់ភាពសប្បាយ រីករាយជូនភ្ញៀវដែលមើលទៅហាក់ដូចជានារីដែលមិនចេះខ្វល់ខ្វាយ និងមានទុក្ខព្រួយអ្វីនៅក្នុងខ្លួនសោះឡើយ។ នេះជាសម្តីរបស់កញ្ញា សុភស្ត អាយុ ២៤ឆ្នាំ ជានារីបម្រើសេវាកម្សាន្តនៅក្នុងហាងខារ៉ាអូខេមួយកន្លែងនៅម្តុំផ្លូវព្រះសីហនុជាប់ខារ៉ាអូខេគិរីរម្យ។

កញ្ញាបានបន្តថា ជាស្ត្រីកំដរភ្ញៀវមានការលំបាកខុសពីកិច្ចការរបស់នារីដទៃទៀត ដែលពួកគេមានសមត្ថភាព និងមានចំណេះដឹងខ្ពស់អាចរកបានការងារល្អៗ ហើយពួកគេមានភាពរីករាយ និងសប្បាយចិត្តនឹងការងារដែលគេកំពុងធ្វើ។ បើទោះបីជាការងារពួកគាត់មានការលំបាកខ្លះ តែពួកគាត់អាចមានពេលវេលា និងថ្ងៃសម្រាកគ្រប់គ្រាន់។

សម្រាប់ការងារនារីកំដរភ្ញៀវនៅក្នុងហាងខារ៉ាអូខេវិញត្រូវបានសុភស្ត និយាយថា គាត់ជួបផលលំបាកជាច្រើន។ រៀងរាល់ថ្ងៃភ្ញៀវតែងតែបង្ខំឲ្យគាត់ញ៉ាំគ្រឿងស្រវឹងច្រើន បើគាត់មិនញ៉ាំទេ ភ្ញៀវនឹងខឹងហើយប្រាប់មេការឲ្យដូរចេញ នឹងត្រូវមេការស្តីឲ្យទៀត។ កញ្ញាបន្តថា ពេលខ្លះគាត់ត្រូវបានភ្ញៀវលូកលាន់បំពានលើរូបកាយ ហើយគាត់បានបដិសេធមិនឲ្យលូកលាន់ដោយគាត់ប្រកែក ភ្ញៀវក៏ឲ្យគាត់ចេញពីបន្ទប់ និងមិនឲ្យលុយធីបនោះទេ។

កញ្ញាបានបន្តទៀតថា ដោយការងារនេះត្រូវទទួលទានគ្រឿងស្រវឹងច្រើនពីមួយថ្ងៃទៅមួយថ្ងៃ ដែលមានថ្ងៃខ្លះគាត់ធ្លាក់ខ្លួនឈឺ ហើយធ្វើទុក្ខខ្លាំងជាងគេគឺក្រពះ ដែលធ្វើឲ្យគាត់មិនអាចទៅធ្វើការរួច ហើយថែមទាំងត្រូវថៅកែហាងកាត់ប្រាក់ខែមួយថ្ងៃ៥ដុល្លារទៀត។

ដោយខ្លាចត្រូវថៅកែហាងកាត់ប្រាក់ខែ នឹងអត់បានលុយធីបផង កញ្ញា សុភស្ត ប្រាប់ថា ពេលខ្លះគឺត្រូវបង្ខំចិត្តទៅធ្វើការទាំងឈឺបើមិនទៅគឺអត់មានលុយសម្រាប់ចាយប្រចាំថ្ងៃទេ ព្រោះប្រាក់ខែ១១០ដុល្លារក្នុងមួយខែ ជាចំនួនមិនគ្រប់គ្រាន់សម្រាប់ចិញ្ចឹមជីវិត និងថ្លៃផ្ទះ ថ្លៃទឹកភ្លើងនោះទេ ពីព្រោះខ្ញុំត្រូវចំណាយយ៉ាងហោច ១៥០០០ រៀល សម្រាប់ម្ហូប និងការផាត់មុខ ធ្វើសក់ជារៀងរាល់ថ្ងៃ។

ងាកចេញពី សុភស្ត មកមើល ណាគ្រី និងចាន់ណា វិញក៏ជានារីបម្រើការកម្សាន្ត ក៏បានរៀបរាប់ប្រាប់អំពីទុក្ខលំបាកផ្ទាល់ខ្លួនឲ្យអ្នកនាំសារដឹងផងដែរ។

ណាគ្រី នាងជានារីដែលមកពីខេត្តកំពង់ឆ្នាំង ដែលរស់នៅក្នុងស្ថានភាពក្រីក្រ នឹងដោយសារមានការលួងលោមពីដៃគូសង្សារផងនោះ ណាគ្រីបានសម្រេចចិត្តចាកចេញពី ស្រុកកំណើតមកធ្វើការក្នុងភោជនីយ៍ដ្ឋានមួយកន្លែង ក្នុងរាជធានីភ្នំពេញ កាលពីនាងមានអាយុ ១៩ឆ្នាំ តែតាមពិតនាងត្រូវបានមេខ្យល់យកមកលក់ឲ្យធ្វើជានារីបម្រើការកម្សាន្តនៅក្នុងផ្ទះបនមួយកន្លែង។

ណាគ្រីបានប្រាប់ថា គាត់ពុំដែលស្គាល់គេនោះទេ ដោយគេបបួលដោយប្រាប់ម្តាយនាងថា ធ្វើការរត់តុនៅហាងម៉ាស្សា តែនាងពុំដែលបានដឹងទេ ដោយគេបានឲ្យនាងអង្គុយចាំតែប៉ុណ្ណោះ ក៏ប៉ុន្តែនាងត្រូវបានគេយកមកលក់ ឲ្យធ្វើជានារីបម្រើការកម្សាន្ត ដោយនាងគ្រាន់គិតថា នាងគ្រាន់តែធ្វើការជាអ្នកម៉ាស្សាម្នាក់ប៉ុណ្ណោះ។

ណាគ្រីត្រូវបានមេបន បង្ខំឲ្យរួមភេទជាមួយបុរសជាច្រើននាក់ក្នុងមួយថ្ងៃ។ ថ្ងៃមួយ ណាគ្រី សម្រេចចិត្តរត់ចេញពីផ្ទះបនបានសម្រេច ក៏ប៉ុន្តែ នាងមិនត្រូវបាន រួចផុតពីជីវិតនារីបម្រើការកំសាន្តនោះទេ។ ណាគ្រីត្រូវបានផ្លាស់ប្តូរពីនារីបម្រើការកំសាន្ត នៅក្នុងផ្ទះបន មកជានារី រកស៊ីបម្រើភ្ញៀវរបស់នាងដោយឯករាជ្យវិញម្តង។

មានន័យថានាង យកទីកន្លែងផ្សេងៗ ដូចជាតាមក្លិបរាត្រី សួនច្បារសារធារណៈ ធ្វើជាកន្លែងទទួលអតិថិជនរបស់នាង។

ណាគ្រីបានបន្ថែមថា នាងតែងតែទទួលភ្ញៀវរបស់នាង ជាធម្មតារៀងរាល់ថ្ងៃ ដោយភ្ញៀវរបស់បានឲ្យតម្លៃខ្លួននាង ១០ដុល្លាសហរដ្ឋអាមេរិច ដោយនាងធ្វើបែបនេះអស់រយៈពេល ជាង១០ឆ្នាំមកហើយ។

ណាគ្រីប្រកបរបរបែប អស់រយៈពេលជាច្រើនឆ្នាំទើប ណាគ្រីសម្រេចចិត្តប្រាប់ការពិតពីការងាររបស់នាង ដល់ម្តាយនាង។

នៅក្នុងជីវិតជា នារីបម្រើការកំសាន្ត ណាគ្រី រកប្រាក់ចំណូលបានពី ១ម៉ឺនរៀល ទៅ១៥០០០ រៀល ក្នុងមួយដង។ ដោយនាងអាចរកភ្ញៀវរបស់នាងបានចន្លោះពី ៥ ទៅ ៦នាក់ក្នុងមួយថ្ងៃ។ បន្ថែមលើសពីនេះ ណាគ្រី បានបញ្ជាក់ថា មានភ្ញៀវខ្លះបានធ្វើការ តិះដៀលនាង និងមានភ្ញៀវខ្លះមិនបានឲ្យលុយនាងទៀតផង។

ឆ្លងកាត់មុខរបរជា នារីបម្រើការកំសាន្តសម្រាប់បុរសនោះ ណាគ្រី បានបន្សល់កូន ២នាក់ដោយគ្មានឪពុក ដោយកូនទាំង២នាក់នោះត្រូវបាន ទទួលការមើលថែពី ជីដូននៅឯស្រុកកំណើតរបស់នាង ហើយទទួលការសិក្សារៀនសូត្រ ដែលមានការឧបត្ថម្ភពីម្តាយដែលជានារី ប្រកបរបរបម្រើការកម្សាន្ត។

*ដោយ ផល សុផានិត*



Messenger -103.indd 8 6/22/2017 5:27:17 PM

## នាយករដ្ឋមន្ត្រីស្នើកុំឲ្យមានទស្សនៈឆ្វេងពេកនិងស្តាំពេកនៅក្នុងការអភិវឌ្ឍ

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានស្នើឲ្យក្រសួងទេសចរណ៍ និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក៏ដូចជាដៃគូអភិវឌ្ឍន៍ សូមកុំមានទស្សនៈឆ្វេងពេក និង ស្តាំពេក នៅក្នុងក្របខណ្ឌនៃការអភិរក្សទីក្រុងបេតិកភណ្ឌ។

សម្តេចតេជោបានថ្លែងបែបនេះនៅក្នុងពិធីបើកកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍នៃដៃគូសន្ទនាសហប្រតិបត្តិការអាស៊ីលើកទី ២ និងសន្និសីទអន្តរជាតិលើកទី១ស្តីពីទេសចរណ៍ប្រកបដោយនិរន្តរភាព និងទីក្រុងបេតិកភណ្ឌថា ខ្ញុំបានជួបប្រទះលើបញ្ហានេះច្រើនរួចមកហើយ សូម្បីតែនៅទីក្រុងភ្នំពេញនៅក្នុងដំណាក់កាលមួយនោះយើងទុកផ្ទះរាប់រយផ្ទះដើម្បីធ្វើជាផ្ទះសម្រាប់ការអភិរក្ស ពេលនោះប្រជាជនមានការស្រែកគ្រប់ទីកន្លែង។ ខ្ញុំបានទៅមើលដល់ទីកន្លែងវាស្ទើរតែបាក់ទៅហើយៗអ្នកត្រូវការដីធ្លីកន្លែងនោះ គឺត្រូវការធ្វើផ្ទះស្អាត គេមិនត្រូវធ្វើការនៅផ្ទះនោះទេ ក៏ប៉ុន្តែបែរជាយើងលើកបញ្ជីយ៉ាងច្រើនដើម្បីធ្វើការអភិរក្ស ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ការអភិវឌ្ឍន៍និងអភិរក្សត្រូវតែមានតុល្យភាព ដូចជានៅទីក្រុងមួយចំនួនអគារចាស់ដែលបន្សល់ទុកជាអគាររដ្ឋគឺចាំបាច់ថែទាំការពារវា ប៉ុន្តែយើងមិនអាចដាក់ម៉ាទីក្រុងទាំងអស់មិនអោយមានការអភិវឌ្ឍនោះទេ។ "នេះជាចំណុចដែលខ្ញុំសុំផ្តល់ការយកចិត្តទុកដាក់ ទៅលើបញ្ហាអភិរក្ស និងអភិវឌ្ឍន៍។ កុំអោយវាទៅជាគិតតែពីអភិរក្សដោយមិនខ្វីគិតពីការអភិវឌ្ឍ ហើយគិតតែពីការអភិវឌ្ឍ ដោយមិនខ្វីគិតពីអភិរក្ស ចំណុចនេះវានឹងនាំទៅដល់ការរំខានទៅដល់ការអភិវឌ្ឍរបស់យើងទៅវិញទេ "។

## កាតាកំពុងមានជម្លោះជាមួយនឹងប្រទេសជិតខាង

ប្រទេសកាតា នៅក្នុងពេលបច្ចុប្បន្ននេះកំពុងតែមានជម្លោះការទូតធ្ងន់ធ្ងរជាមួយនឹងបណ្តាប្រទេសជិតខាងនៅក្នុងតំបន់មជ្ឈឹមបូព៌ា ហើយប្រទេសមួយនេះកំពុងតែប្រឈមមុខនឹងវិបត្តិស្បៀង និងការធ្លាក់ចុះពាណិជ្ជកម្មព្រមទាំងសេវាកម្ម។

ប្រទេសដ៏តូចមួយនៅមជ្ឈឹមបូព៌ា ត្រូវបានប្រទេសមួយចំនួនដែលរួមទាំង អារ៉ាប៊ីសាអូឌីត ដែលជាគូប្រជែងដ៏ធំរបស់អ៊ីរ៉ង់ បានកាត់ផ្តាច់ចំណងទាក់ទងការទូត ដោយចោទប្រកាន់ថាប្រទេសនេះថា បានផ្តល់ហិរញ្ញវត្ថុដល់ក្រុមភេរវកម្ម ប៉ុន្តែប្រទេសកាតាបានបដិសេធការចោទប្រកាន់នេះ។

ប្រទេសនៅក្បែរខាងកាតា លើកលែងអ៊ីរ៉ង់ ក្រៅពីប្រកាសកាត់ផ្តាច់ទំនាក់ទំនងការទូតចេញ បានប្រកាសបិទផ្លូវអាកាសមិនឲ្យក្រុមហ៊ុនអាកាសចរណ៍កាតា ប្រើប្រាស់ដែនអាកាសរបស់ពួកគេថែមទៀត ជាហេតុបណ្តាលឲ្យប្រទេសនេះកំពុងតែធ្លាក់នៅក្នុងវិបត្តិនៃការខ្វះស្បៀងអាហារ។ ឆ្លើយតបនឹងវិបត្តិនេះ អ៊ីរ៉ង់បានប្រកាសបញ្ជូនស្បៀងអាហារ តាមយន្តហោះ៥គ្រឿងទៅប្រទេសកាតាចំពេលដែលមានការហ៊ុមព័ទ្ធក្នុងតំបន់។

លោក សារុខ នូសាបាឌី អ្នកនាំពាក្យក្រុមហ៊ុនអាកាសចរណ៍អ៊ីរ៉ង់បាននិយាយប្រាប់ទីភ្នាក់ងារសារព័ត៌មានបារាំងថា រហូតមកដល់ពេលនេះ យន្តហោះចំនួន៥គ្រឿងដែលដឹកស្បៀងហារទៅកាន់ប្រទេសកាតា ដោយយន្តហោះមួយគ្រឿងៗដឹកស្បៀងអាហារទម្ងន់ជិត៩០តោនត្រូវបានបញ្ជូនទៅកាន់ប្រទេសនេះកាលពីថ្ងៃទី១១ខែមិថុនា។

## សភាជប៉ុនអនុម័តបើកផ្លូវសម្រាប់ការដាក់រាជ្យជាលើកទីមួយរបស់ព្រះចៅអធិរាជ

សភាជប៉ុននៅដើមខែមិថុនាបានអនុម័តច្បាប់មួយដែលបើកផ្លូវសម្រាប់ព្រះចៅអធិរាជ អាគីហ៊ីតូ ដែលមានព្រះជន្ម៨៣វស្សា ដើម្បីដាក់រាជ្យនៅក្នុងអ្វីដែលជាការដាក់រាជ្យលើកទីមួយក្នុងរយៈពេលជាង២សតវត្សរ៍ចុងក្រោយនេះ។

គួររំលឹកថា ព្រះចៅអធិរាជ អាគីហ៊ីតូ ព្រះអង្គនេះបានធ្វើឱ្យមានការភ្ញាក់ផ្អើលខ្លាំងនៅក្នុងប្រទេស និងពិភពលោកកាលពីរដូវក្តៅមុន នៅពេលដែលព្រះអង្គបានបង្ហាញបំណងចង់ដាក់រាជ្យ បន្ទាប់ពីបានឡើងសោយរាជ្យអស់រយៈពេលជាង៣០ឆ្នាំ នៅក្រោមហេតុផលថាព្រះអង្គមានព្រះជន្មកាន់តែចាស់និងមានបញ្ហាសុខភាព។

អ្នកវិភាគបានអះអាងថា ការអនុម័តច្បាប់នេះដោយសភា បាននាំឱ្យមានបញ្ហាប្រឈមមួយ គឺចាប់តាំងពីមិនមានច្បាប់សម្រាប់ដោះស្រាយចំពោះករណីព្រះចៅអធិរាជចូលនិវត្តន៍ខណៈដែលគេដឹងថា ព្រះអង្គសោយរាជ្យរហូតអស់មួយព្រះជន្ម។ ជប៉ុនត្រូវបានគេដឹងថា គឺជាប្រទេសមួយ ដែលមានព្រះចៅអធិរាជគង់ជានិមិត្តរូបរបស់ប្រទេសដ៏ចំណាស់មួយនៅលើពិភពលោក។ ព្រះចៅអធិរាជគង់ជានិមិត្តរូប ប៉ុន្តែព្រះអង្គមិនកាន់អំណាចឡើយ។

បន្ទាប់ពីការដាក់រាជ្យ ព្រះចៅអធិរាជបន្ទាប់របស់ជប៉ុនត្រូវបានគេរំពឹងថា ធ្លាក់ទៅលើ បុត្រាច្បងរបស់ព្រះអង្គ គឺព្រះអង្គម្ចាស់ ណារូហ៊ីតូ ដែលជាព្រះរាជទាយាទ។

## ពន្ធដារ ប្រកាសអនុវត្តពន្ធអាករលើតម្លៃបន្ថែម១០ ភាគរយពីសេវាកម្មហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសអនុវត្តពន្ធអាករលើតម្លៃបន្ថែម១០ភាគរយលើសេវាកម្មហិរញ្ញវត្ថុ។

យោងទៅតាមសេចក្តីប្រកាសព័ត៌ មានកាលពីថ្ងៃទី៧ មិថុនា ២០១៧ អគ្គនាយកដ្ឋានពន្ធដារ បានប្រកាសអនុវត្តពន្ធអាករលើតម្លៃបន្ថែមនេះ ដោយលើកឡើងថា សេវាហិរញ្ញវត្ថុដែលមិនជាប់ពន្ធអាករលើតម្លៃបន្ថែមគឺមានដូចជា សេវាហិរញ្ញវត្ថុមូលដ្ឋាន ដែលកំណត់តែទៅលើប្រតិបត្តិការទទួលប្រាក់បញ្ញើ និងការផ្តល់ឥណទាន តែមិនរាប់បញ្ចូលកម្រៃសេវាផ្សេងៗ។

ប្រភពដដែលបានលើកឡើងថា ការប្រកាសនេះមិនមែនជារឿងថ្មីនោះទេ។ ការប្រកាសនេះ គឺបានប្រកាសតាំងពីយូរមកហើយ។

ប្រភពដដែលបានបញ្ជាក់ថា ការដាក់ឲ្យអនុវត្តអាករលើតម្លៃបន្ថែម១០%នេះមិនមែនជាការបង្កើត ឬអនុវត្តពន្ធថ្មីនោះទេ។ ប្រភពបានបញ្ជាក់ថា ពន្ធនេះត្រូវបានដាក់អនុវត្តតាំងពីឆ្នាំ១៩៩៩មកម្ល៉េះ ប៉ុន្តែរដ្ឋាភិបាលបានអនុគ្រោះមិនយកពន្ធនេះដើម្បីសម្រួលដល់ជីវភាពប្រជាពលរដ្ឋ។

ជុំវិញការប្រកាសអនុវត្តប្រមូលយកពន្ធនេះ អ្នកវិភាពបានអះអាងថា សេវាដែលត្រូវជាប់ពន្ធនេះគឺរាប់តាំងពី សេវាផ្ញើប្រាក់ ការទទួលកម្ចី សេវាផ្នែកច្បាប់ សេវាផ្នែកគណនេយ្យ និងសេវាផ្សេងៗទៀត។ ហើយការប្រមូលពន្ធនេះ នឹងជួយបង្កើតចំណូលជាតិបន្ថែមដល់រដ្ឋាភិបាល ប៉ុន្តែពលរដ្ឋក៏ត្រូវជាប់កាតព្វកិច្ចបង់ពន្ធខ្ពស់ជាងមុន។

តាមការវិភាគការប្រកាសដាក់ឲ្យអនុវត្តប្រមូលពន្ធបន្ថែម ពីលើសេវាកម្មហិរញ្ញវត្ថុខាងលើនេះ អាចឲ្យរដ្ឋប្រមូលប្រាក់ចំណូលបានប្រមាណជា ៣០លានដុល្លារ ក្នុងមួយឆ្នាំ សម្រាប់បម្រើសេចក្តីត្រូវការផ្សេងៗនៅក្នុងការអភិវឌ្ឍន៍ជាតិ។

## កម្ពុជាប្រកាសស្នើដាក់ទីក្រុង ៣ ទៅជាទីក្រុងបេតិកភណ្ឌ

ក្រសួងទេសចរណ៍កម្ពុជាបានប្រកាសពីការដាក់ស្នើទីក្រុងសំខាន់ៗ ចំនួន៣ឲ្យទៅជាទីក្រុងបេតិកភណ្ឌ សម្រាប់ការអភិវឌ្ឍទេសចរណ៍បេតិកភណ្ឌក្នុងឱកាសសន្និសីទអន្តរជាតិស្តីអំពីទេសចរណ៍បេតិកភណ្ឌ ចាប់ពីថ្ងៃទី១៤-១៥ ខែមិថុនា នៅទីក្រុងសៀមរាប ខេត្តសៀមរាប។ ប្រភពដដែលបានថ្លែងថា ទីក្រុងទាំងបីនោះ គឺរួមមានទីក្រុងបាត់ដំបង ក្រុងក្រចេះ និងក្រុងកំពត ។

លោក ទិត ចន្ថា រដ្ឋលេខាធិការក្រសួងទេសចរណ៍បានថ្លែងបញ្ជាក់អំពីការប្រកាសស្នើសុំចុះបញ្ជីទីក្រុងទាំងបីនេះថា ទីក្រុងទាំងនេះមានតម្លៃសម្រាប់ទាំងការអភិរក្ស និងអភិវឌ្ឍន៍ជាពិសេសគឺសម្រាប់សេវាកម្មទេសចរណ៍ ដូច្នេះហើយបានជាក្រសួងសហការជាមួយនឹងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈរៀបចំសំណើរចុះបញ្ជីនេះឡើង។

ប្រភពដដែលបានបន្តថា សេចក្តីស្នើនេះបានត្រូវធ្វើឡើងនៅក្នុងអំឡុងពេលដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី នៃដៃគូសន្ទនាសហប្រតិបត្តិការអាស៊ី លើកទី ២ និងសន្និសីទអន្តរជាតិលើកទី១ ស្តីពីទេសចរណ៍ ប្រកបដោយនិរន្តរភាព និងទីក្រុងបេតិកភណ្ឌ ក្រោមប្រធានបទ "ការអភិរក្ស និងការការពារទីក្រុងបេតិកភណ្ឌ"។

ទីក្រុងក្រចេះ ត្រូវបានគេដឹងថា គឺជាទីប្រជុំជនមួយដែលសណ្ឋិតតាមបណ្តោយដងទន្លេមេគង្គ នៅក្នុងខេត្តក្រចេះ។ ទីក្រុងនេះ ត្រូវបានគេដឹងថា គឺជារមណីដ្ឋានដ៏ទាក់ទាញមួយ ដែលអាចនឹង ផ្តល់នូវទស្សនីយភាពដ៏ប្រពៃសម្រាប់ជាធនធានអភិរក្សជាសម្បត្តិវប្បធម៌ និងសម្បត្តិធម្មជាតិមួយនៅកម្ពុជា។ នៅទីនោះមានសំណង់អាគារចំណាស់ៗសម័យអាណានិគមនិយមបារាំងច្រើន។

កំពតត្រូវបានគេដឹងថា គឺជាទីក្រុងមួយ ដែលមានទីតាំងតាមបណ្តោយដងស្ទឹងចុះទៅសមុទ្រ។ ទីនោះ គឺជារមណីដ្ឋានប្រវត្តិសាស្ត្រនិងធម្មជាតិ ព្រមទាំងវប្បធម៌កាត់ថ្លៃមិនបានមួយនៅក្នុងប្រទេសកម្ពុជា។ ទីក្រុងនេះ គឺជាច្រកទៅកាន់រមណីដ្ឋានភ្នំបូកគោទៅឆ្នេរសមុទ្រកែប និងរមណីដ្ឋានទឹកធ្លាក់ទឹកឈូ និងចំការធុរេនដ៏ល្បីល្បាញនៅកម្ពុជា។

ទីក្រុងបាត់ដំបងមានទីតាំងតាមបណ្តោយដងស្ទឹងសង្កែ នៅភាគនិរតីនៃបឹងទន្លេសាប គឺជាបេះដូងនៃខេត្តជម្រុកស្រូវរបស់កម្ពុជា។ ទីនោះសំបូរទៅដោយអាគារសំណង់បុរាណសម័យអាណានិគមនិយមបារាំង និងផ្ទះបុរាណតាមប្រពៃណីបុរាណខ្មែរក្រៅពីនោះ គឺមានសំណង់ស្ថាបត្យកម្មបុរាណតាំងពីសម័យអង្គរល្អាងទឹកធ្លាក់ជាដើម។

# ឱសថបុរាណនៅតែមានគុណតម្លៃសម្រ

ខណៈដែលសេដ្ឋកិច្ច និងកម្រិតជីវភាពមានការរីកចម្រើនទៅមុខរហូតដល់ប្រជាពលរដ្ឋមួយ ចំនួនអាចមានលទ្ធភាពស្វែងរកសេវាថែទាំនិងព្យាបាលសុខភាពនៅបរទេស តាំងពីវៀតណាម ថៃ... រហូតដល់ចិន កូរ៉េ ឥណ្ឌា អាមេរិក បារាំងក្តី ប៉ុន្តែទោះបីជាយ៉ាងណាក៏នៅតែមិនអាចទាត់ចោលនូវគុណតម្លៃនៃឱសថបុរាណ។

ឱសថបុរាណដែលកំពុងតែត្រូវបានប្រជាពលរដ្ឋកម្ពុជាប្រើប្រាស់ដើម្បីព្យាបាលជំងឺនៅពេលបច្ចុប្បន្ននេះ គឺភាគច្រើនគឺជារុក្ខជាតិ ដែលមានដុះនៅតាមភូមិស្រុក រហូតដល់រុក្ខជាតិ ផល្លានុផលដែល ប្រមូលពីតំបន់ព្រៃភ្នំ។ នេះបើតាមអ្វីដែលប្រជា-ពលរដ្ឋកម្ពុជាកំពុងតែប្រើប្រាស់បានរៀបរាប់ប្រាប់ អ្នកនាំសារកាលពីពេលថ្មីៗនេះ។

លោក លី លឹមហេង ជាប្រជាពលរដ្ឋវ័យកណ្តាលមួយរូបបានថ្លែងថា មកដល់ពេលនេះ លោកជាពិសេសគឺម្តាយរបស់លោកកំពុងតែទទួលទានឱសថបុរាណដើម្បីជួយព្យាបាលជំងឺមហារីក។

លោក លឹមហេង បានរៀបរាប់ថា សម្រាប់គាត់មិនមានជំងឺអ្វីធំដុំទេ គឺត្រឹមតែលើសជាតិស្ករ ប៉ុន្តែអ្នកដែលធ្ងន់នោះគឺម្តាយរបស់គាត់ ដែលមកដល់ពេលនេះគឺមានវ័យ ៧៥ឆ្នាំ កំពុងតែប្រឈមមុខនឹងជំងឺមហារីកស្បូន និងជំងឺទឹកនោមផ្អែម។

លោកបានបញ្ជាក់ថា "គាត់មានជំងឺមហារីកមាត់ស្បូន កម្រិត៣ មានដុំគិសនៅពោះវៀន និងមានបញ្ហាទឹកនោមផ្អែមថែមទៀត ដូច្នេះពេទ្យមិនហ៊ានធ្វើអ្វីទាំងអស់ក្រៅពីឲ្យថ្នាំបំបាត់ការឈឺចាប់ និងកំណត់អាយុគាត់។

លោកបានថ្លែងបន្តទៀតថា គាត់រកឃើញជំងឺនេះជាងមួយឆ្នាំមកហើយ ប៉ុន្តែគ្រូពេទ្យទាំងនៅវៀតណាម និងថៃ សុទ្ធតែថាឲ្យកាត់ចិត្តនិងត្រៀមខ្លួន។ ពីព្រោះគាត់ចាស់ ខ្សោយកម្លាំង ហើយមានជំងឺសុទ្ធតែជាប្រភេទដែលមានគ្រោះថ្នាក់នៅវ័យជរា ដោយវះកាត់ក៏មិនកើត ចាក់គីមីក៏គេមិនហ៊ាន ហើយបានណែនាំថ្នាំម៉្យាងមានតម្លៃថ្លៃ ដោយមួយគ្រាប់ជាង ២០ ដុល្លារ។ នៅស្រុកខ្មែរក៏មិនមានដែរ។

លោកបានបន្តថា ដោយសារតែថ្នាំនោះវាថ្លៃ យើងខ្វះលទ្ធភាព គាត់ និង បងប្អូនក៏ខ្វះលទ្ធភាព គាប់ជួនថ្ងៃមួយក៏ទៅស៊ើបសួរៗគ្នាស្រាប់តែល្បីថា ស្លឹកទៀប-បារាំងអាចជួយម្តាយគាត់បាន ក៏បានយកទៅពិគ្រោះជាមួយពេទ្យ។

លោកបានបន្តថា ពេលពិគ្រោះជាមួយនឹងពេទ្យទាំងនៅវៀតណាមក្តី និងពេទ្យនៅថៃក្តី គឺមិនបានបដិសេធនូវគុណតម្លៃនៃស្លឹកទៀបបារាំនេះដែរ ដោយគ្រាន់តែបញ្ជាក់ថា តាមក្បួនវេជ្ជសាស្ត្រ ហើយតាមការស្រាវជ្រាវដែលពួកគេធ្លាប់អាន គឺស្លឹកទៀបបារាំងត្រូវបានគេអះអាងថា អាចមានប្រយោជន៍ដូច្នេះលោកក៏សាកល្បង។

លោកបានបញ្ជាក់ថា "ជាងមួយឆ្នាំហើយម្តាយខ្ញុំ ហាក់នូវដដែល ហើយអាថ្នាំ បំបាត់ការឈឺចាប់ គឺបានបន្ថយតែសុខភាពគាត់ដូចជាមនុស្សចាស់ទូទៅដែរ"។

លោកបានបន្តទៀតថា ស្លឹកទៀបបារាំងនេះ គឺគ្មានអ្វីក្រៅពីយកស្លឹកវាមកហាលហើយយកទៅដាំទឹកផឹកធម្មតា ដូចជាទឹកតែ ដោយឡែករសជាតិវាក៏មិនជូរមិនចត់តែផ្អុយទៅវិញគឺឈ្ងុយ ដែលមានពេលខ្លះគាត់ក៏បានផឹកទឹកនោះជាមួយនឹងម្តាយដែរ ដោយឮគេថា វាអាចជួយព្យាបាលជំងឺមួយរយមុខ។

លោក ដោក សុភា ជាប្រជាពលរដ្ឋវ័យកណ្តាលមួយរូបបានថ្លែងថា សព្វថ្ងៃនេះគាត់កំពុងតែរស់នៅជាមួយនឹងជំងឺរលាកថ្លើមប្រភេទ សេ ដែលគ្រូពេទ្យទាំងក្នុងស្រុក និងក្រៅស្រុកថា កំពុងតែឈានទៅដល់ជំងឺក្រិនថ្លើម ហើយទាមទារការព្យា-បាលជាបន្ទាន់។



លោកបានបន្តថា គ្រូពេទ្យទាំងនៅខ្មែរ និងនៅវៀតណាម សុទ្ធតែអះអាងថា ត្រូវតែព្យាបាលជាបន្ទាន់ បើមិនដូច្នេះទេ គឺមានគ្រោះថ្នាក់ ហើយតម្លៃនៃការព្យាបាលនោះគឺ ការចាក់ថ្នាំដែលនៅមុខមួយម្ភុលមានតម្លៃដល់ទៅរយដុល្លារ ហើយត្រូវព្យាបាលពី ៣ទៅ ៦ខែ ហើយអាចលោតដល់មួយឆ្នាំ សរុបទៅគឺអាចអស់ ពីជាងមួយម៉ឺនដុល្លារទៅជិត ៣ម៉ឺនដុល្លារ។

លោកបានបញ្ជាក់ថា "បើព្យាបាលតម្លៃពី ៤.០០០ ទៅ ៥.០០០ដុល្លារ គឺអាចមានលទ្ធភាពតែនេះដល់ថ្នាក់ ម៉ឺនមានលុយឯណា ចឹងមានតែរកឱសថបុរាណ"។

លោកបានបន្តថា រហូតមកដល់សព្វថ្ងៃនេះ គាត់បានស្វែងរកការព្យាបាលតាមក្បួនវេជ្ជសាស្ត្របុរាណ ពីព្រះសង្ឃមួយអង្គនៅម្តុំភ្នំបាសិទ ហើយតាំងពីព្យាបាលមកមានអារម្មណ៍ថា ស្រឡះៗខ្លួនដែរ។

លោកបានបញ្ជាក់ថា "គ្រូពេទ្យទំនើបគេប្រាប់ខ្ញុំថា តែក្រិនហើយ គឺយ៉ាងយូររស់បានតែ ៦ខែអីទេ ហើយថ្លើមខ្ញុំអាចវិវត្តទៅក្រិននេះលឿន ដោយសារតែសាច់ថ្លើម គឺវាមានស្ថានភាពអាក្រក់ ដោយសារតែខ្ញុំផឹកស្រា តែឥឡូវនេះដូចជាជាងពីរ

## វិធីព្យាបាលជំងឺពីរប្រភេទងាយផុត

យោងទៅតាមគេហទំព័ររបស់លោក អ៊ាង សុផល្លែត អនុរដ្ឋលេខាធិការក្រសួងបរិស្ថានបានឲ្យដឹងថា ជំងឺពីរប្រភេទគឺអាចព្យាបាលជាមួយ នឹងរុក្ខជាតិដែលងាយរកបំផុត។

ជំងឺទាំងពីរនោះ គឺជំងឺក្រួសនៅក្នុងថង់ប្រមាត់ និងជំងឺក្អក។

លោកបានចែករំលែកតាមគេហទំព័រនោះថា ជំងឺក្រួសក្នុងថង់ប្រមាត់គេអាចព្យាបាលវាតែជាមួយ នឹងស្លឹកចេកណាំវ៉ា ប៉ុណ្ណោះ។ លោកបានបន្តថា ស្លឹកចេកណាំវ៉ានោះ គឺជាស្លឹកចាស់ ដោយយកវាទាំងស្រស់ ឬហាលឱ្យស្ងួតទៅដាំទឹក ៣០នាទី ហើយយកមកផឹកដូចទឹកតែ នោះប្រសិទ្ធិភាពនឹងបានឃើញ។

ដោយឡែកជំងឺក្អកវិញ គេបានរកឃើញឱសថបុរាណធម្មជាតិសម្រាប់ព្យា-បាលជំងឺនេះ គឺប្រើប្រាស់ប្រភេទរុក្ខជាតិជីស្លឹកត្រចៀកជ្រូក ។

លោកបានឲ្យដឹងថា វិធីធ្វើថ្នាំនេះ គឺងាយស្រួលបំផុត គឺគ្រាន់តែយក ស្លឹកត្រចៀកជ្រូកមកច្របាច់ជាមួយទឹក ហើយច្រោះយកកាកចេញ រួចដាក់អំបិលលាយស្ករបន្តិច ហើយពិសាពេលព្រឹក ១កែវ គឺស្រេច មិនតែប៉ុណ្ណោះវាថែមទាំងជួយបង្ការជំងឺ គ្រុនផ្តាសាយ និងរលាកទងសួតទៀតផងដែរ។

Messenger -103.indd 10 6/22/2017 5:27:24 PM

# រាប់ប្រជាពលរដ្ឋខ្មែរគ្រប់ស្រទាប់វណ្ណៈ


ថតដោយ រិទ្ធី

ថ្នាំហើយដូចជាមិនទាន់អីទេ ក៏ចេះតែ ផឹកថ្នាំបុរាណរបស់លោកបន្តទៅ"។

លោកបានបន្ថែមទៀតថា ថ្នាំពេទ្យរាប់ម៉ឺន មានលុយឯណា តែថ្នាំឱសថបុរាណដាវពីព្រះសង្ឃគឺមួយផ្ទាំង ២០.០០០រៀល ដាំផឹកកន្លះខែ។

លោកបានបន្តថា នៅពេលពិនិត្យ ពេទ្យគេរាប់មេរោគថ្លើមខ្ញុំឃើញមានជាង ៣ លាន តែដល់ពេល ផឹកថ្នាំបុរាណនេះទៅ ពេលពិនិត្យទៅលើកក្រោយ ពេទ្យថា ធ្លាក់ចុះ ហើយមកដល់ពេលនេះ ក៏ខានទៅពិនិត្យយូរហើយ ប៉ុន្តែនៅតែបន្តផឹកឱសថបុរាណនេះបន្តដដែល។

លោកបានបន្តថា គាត់ក៏មិនដឹងថាឱសថបុរាណដែលគាត់បានដាវពីព្រះសង្ឃមកដាំផឹកនោះ ផ្សំពីអ្វីខ្លះនោះទេ ប៉ុន្តែតាមដែលលោកបានមើល និងយល់នោះ គឺអាចមានតាំងពីឫសស្មៅ ឫសឫស្សី កូនដើមត្នោត មើមស្មៅក្រវាញជ្រូកជាដើម ...។

ជុំវិញប្រសិទ្ធិភាពនៃឱសថបុរាណនេះ លោក ពេជ្រ សុផល ដែលជាគ្រូឱសថបុរាណមួយរូបបានមានប្រសាសន៍ថា សព្វថ្ងៃនេះ គាត់បានទទួលព្យាបាលជំងឺជាច្រើនដូចជា ជំងឺក្រពះ ទឹកនោមផ្អែម ទឹកនោមប្រៃ ជំងឺទាចទឹក ឈាមសស៊ីឈាមក្រហម របេងឆ្អឹង មហារីកជាដើម។

លោកបានបញ្ជាក់ថា "ឱសថខ្ញុំ គឺផ្សំពីរុក្ខជាតិសុទ្ធ ហើយមានក្បួនវិធីផ្សំត្រឹមត្រូវដែលអ្នកជំងឺជាច្រើនបានទទួលស្គាល់"។

លោកបានបន្តថា អ្នកជំងឺគឺភាគច្រើនទទួលស្គាល់ថា ក្រោយពីពួកគេបានដាវថ្នាំខ្ញុំទៅប្រើប្រាស់ គឺបានធូរអាចបន្តជីវិតទៅមុខទៀតបាន។

ដោយឡែក លោក ម៉ិញ ភារម្យ ដែលត្រូវបានគេដឹងថា ជាអ្នកតំណាងឲ្យឱសថបុរាណភ្នំព្រះអមតៈ បានឲ្យដឹងថា ឱសថបុរាណឃីហោរនេះ គឺផ្សំពីរុក្ខជាតិដែលដុះនៅព្រៃភ្នំសុទ្ធសាធ ហើយអាចព្យាបាលជំងឺបាន ១០០មុខ រាប់តាំងពីឫសដូងបាតកាមរោគឡើងទៅ។

លោកបានបដិសេធនៅក្នុងការផ្តល់នូវប្រភេទរុក្ខជាតិដែលលោកយកមកផ្សំថ្នាំនេះ ដោយអះអាងថា នេះជារូបមន្តសម្ងាត់។

បើទោះបីជាយ៉ាងណាក៏ដោយ ជុំវិញឱសថបុរាណនេះ លោក អ៊ាង សុផល្លែត អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន គឺជាមន្ត្រីរាជរដ្ឋាភិបាលកម្ពុជាមួយរូបដែលតែងតែផ្សព្វផ្សាយអំពីប្រសិទ្ធិភាព និងអំណោយទានពីធម្មជាតិនៃអនុផលរបស់វាចំពោះសុខភាពមនុស្ស។

តាមការស្រាវជ្រាវ និងផ្សព្វផ្សាយលោកអ៊ាង សុផល្លែត តាមបណ្តាញសង្គមគឺបានបង្ហាញថា រុក្ខជាតិដែលមនុស្សដាំដុះ និងរុក្ខជាតិដែលដុះតាមធម្មជាតិ គឺមានផលប្រយោជន៍ជាច្រើនដល់សុខភាពរបស់មនុស្ស ឲ្យតែមនុស្សដឹងអំពីប្រសិទ្ធិភាពរបស់វា។

លោកបានចែករំលែកលទ្ធផលនៃការស្រាវជ្រាវរបស់លោកតាមរយៈបណ្តាញសង្គមហ្វេសបុក និងមានគេហទំព័រមួយដែលនៅក្នុងនោះ គឺសុទ្ធតែជាព័ត៌មានដែលនិយាយអំពីសុខភាព និងកសិកម្ម។ ដោយធម្មជាតិ ដែលមានប្រយោជន៍សម្រាប់មនុស្ស ដែលកំពុងតែរស់នៅក្នុងយុគ្គសម័យ បច្ចេកវិទ្យា និងគីមី។

កាលពីពេលថ្មីៗនេះ លោកបានអះអាងថា គាត់ហ៊ានទទួលទានជ្រូកខ្វៃ ដោយមិនខ្លាចខ្លាញ់ និងមិនខ្លាចខូចរាង គឺដោយសារតែ ដឹងអំពីវិធីធ្វើភេសជ្ជៈបញ្ចុះខ្លាញ់ក្នុងឈាម និងសម្រកក្បាលពោះ។

លោកបានចែករំលែកថា វិធីធ្វើនោះគឺងាយស្រួល ហើយគ្រឿងផ្សំវិញក៏ងាយរកដែរ គឺមានដូចជា ក្រូចឆ្មារ៣ឬ៤ចំណិត, ខ្ញីមស៣កំពិស, ទឹកឃ្មុំ១ស្លាបព្រាបាយ, ទឹកក្តៅ១កែវ លាយចូលគ្នា ហើយទុកពេល ៥នាទី ហើយអាចទទួលទានរាល់ព្រឹកពិសេសគឺរយៈពេល ២០នាទីមុនបរិភោគអាហារ។

លោកបានបញ្ជាក់ថា "លទ្ធផលនឹងទទួលបានផលក្នុងរយៈពេលត្រឹមតែមួយសប្តាហ៍ប៉ុណ្ណោះ"។

*ដោយ អរិយបុត្រ*

## វិធីព្យាបាលជំងឺទឹកនោមប្រៃតាមក្បួនបុរាណខ្មែរ

តាមការចែករំលែករបស់ លោក អ៊ាង សុផល្លែត អនុរដ្ឋលេខាធិការក្រសួងបរិស្ថានដែលបានស្រាវជ្រាវ និងបានផ្សព្វផ្សាយនៅលើគេហទំព័រផ្ទាល់ខ្លួនថា ជំងឺទឹកនោមប្រៃអាចព្យាបាលបានតាមក្បួនបុរាណខ្មែរ ។

លោកបានបន្តថា ជំងឺនេះអាចព្យាបាលបានដោយប្រើប្រាស់ត្រឹមតែរុក្ខជាតិមួយចំនួន ដូចជា គល់ល្ហុង គល់ម្នាស់ គល់រំចេក និង ស្លឹកដង្ហិត តែប៉ុណ្ណោះ ។

លោកបានបន្តថា ដើម្បីព្យាបាលជំងឺនេះ គឺគេត្រូវ ហាលគល់ល្ហុង គល់ម្នាស់ គល់រំចេក ស្លឹកដង្ហិត ឱ្យស្ងួតបន្ទាប់មក យករុក្ខជាតិទាំងនោះក្នុងចំនួនស្មើៗគ្នា ១ក្តាប់ដែលមដាំទឹក១កំសៀវផឹក។ លោកបានបន្តថា ជំងឺនេះអាចព្យាបាលដឹងលទ្ធផលល្អក្នុងរយៈពេល ពីមួយខែ ជាមួយនឹងការផឹក នោះគឺ១ថ្ងៃ ពី ២ ឬ៣កែវប៉ុណ្ណោះ ។

Messenger -103.indd 11 6/22/2017 5:27:29 PM

# គ្រីស្តបរិស័ទចម្រុះជាតិសាសន៍ចំនួន៣៧នាក់ ទទួលអគ្គសញ្ញាលាបថ្ងាស

បេក្ខជន បេក្ខនារីចំនួន ៣៧នាក់មកពីសគមន៍និយាយភាសាផ្សេងៗគ្នា បានទទួល អគ្គសញ្ញាលាបថ្ងាស ក្នុងឱកាសបុណ្យព្រះវិញ្ញាណយាងមក នៅព្រះវិហារកាតូលិកសន្តយ៉ូសែប( ផ្សារតូចភ្នំពេញ )។ ពិធីនេះប្រព្រឹត្តទៅកាលពីថ្ងៃទី០៤ មិថុនា ២០១៧ ដោយមានលោក អូលីវីយេ ជ្មីតអឺស្លែរអភិបាលព្រះសហគមន៍កាតូលិកភ្នំពេញជាអធិបតី និងមានបងប្អូនគ្រីស្តបរិស័ទចូលរួមជាច្រើនកុះករ ដែលពីសហគមន៍គ្រីស្តបរិស័ទនិយាយភាសាអង់គ្លេស សហគមន៍គ្រីស្តបរិស័ទនិយាយភាសាបារាំង សហគមន៍គ្រីស្តបរិស័ទនិយាយភាសាកូរ៉េ និងភាសាខ្មែរ។

មានប្រសាសន៍ក្នុងពេលធម្មទេសនា លោកអូលីវីយេ បានមានប្រសាសន៍ណែនាំដល់គ្រីស្តបរិស័ទដែលមានវត្តមានក្នុងពិធីថា មុនព្រះយេស៊ូយាងឡើងស្ថានមបរមសុខ ព្រះអង្គបានប្រទានសេចក្តីសុខសាន្ត ហើយសេចក្តីសុខសាន្តគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់បំផុត។ លោកបន្តថា ប្រសិនបើគ្មានសេចក្តីសុខសាន្តនៅក្នុងចិត្តយើងនោះទេ នោះទាំងខ្លួនយើងផ្ទាល់ទាំងព្រះសហគមន៍ទាំងក្នុងសង្គម និងពិភពលោកទាំងមូលក៏គ្មានសេចក្តីសុខសន្តិភាពដែរ។

លោកអភិបាលក៏បានជំរុញឲ្យគ្រីស្តបរិស័ទទាំងអស់ យកចិត្តទុកដាក់ថែរក្សាសេចក្តីសុខសាន្តដែលបានទទួលពីព្រះជាម្ចាស់តាមរយៈព្រះវិញ្ញាណ។ ដោយហេតុថា នៅពេលដែលចេញទៅប្រកាសដំណឹងតាមរយៈជីវិតរស់នៅប្រចាំថ្ងៃ ដែលពោរពេញដោយសេចក្តីសុខសាន្ត មានសេចក្តីស្រឡាញ់និងចេះបម្រើគ្នាទៅវិញទៅមក នោះនាំឲ្យខ្លួនយើងម្នាក់ៗអភិវឌ្ឍន៍ខ្លួនឯងផ្ទាល់ និងពិភពលោកទាំងមូល។

លើសពីនេះទៅទៀត លោកអូលីវីយេ បានជំរុញឲ្យគ្រីស្តបរិស័ទយកចិត្តទុកដាក់ក្នុងការលើកលែងទោសឲ្យគ្នាទៅវិញទៅមកយ៉ាងពិតប្រាកដគឺ "មានចិត្តលើកលែងទោស និងលើកលែងទោសពិតៗ មិនត្រឹមតែបបូរមាត់នោះទេ"។ លោកអភិបាលបញ្ជាក់បន្ថែមថា ព្រះវិញ្ញាណដ៏វិសុទ្ធចង់សកម្ម តែសកម្ម ឬមិនសកម្មគឺអាស្រ័យលើចិត្តរបស់យើងដែលខិតខំអនុវត្ត។

បន្ទាប់ពីធម្មទេសនាលោកអូលីវីយេ អភិបាលព្រះសហគមន៍ បានសួរបញ្ជាក់អំពីជំនឿរបស់បេក្ខជនចំពោះព្រះជាម្ចាស់ នៅក្នុងពិធីទទួលអគ្គសញ្ញាលាបថ្ងាស ហើយប្រកាសធម៌ជឿរួមជាមួយគ្រីស្តបរិស័ទ។ បន្ទាប់មករួមជាមួយសន្តបុគ្គលទាំងឡាយ ទូលអង្វរព្រះជាម្ចាស់ដើម្បីសូមព្រះវិញ្ញាណយាងមកគង់សណ្ឋិតជាមួយបេក្ខជនទាំងអស់ សូមឲ្យពួកគេទទួលបានផលផ្លែខាងព្រះវិញ្ញាណគឺដូចជា មានប្រាជ្ញាឈ្លាសវៃ ដឹងខុសដឹងត្រូវ ដឹងអំពីសេចក្តីពិត មានយោបល់ល្អ មានសេចក្តីអង់អាច ប្រព្រឹត្តតាមការណែនាំរបស់ព្រះវិញ្ញាណ និងចេះគោរពកោតខ្លាចព្រះបិតា។

ជាព្រះវិញ្ញាណរបស់ព្រះយេស៊ូជាអម្ចាស់ ដែលប្រទានដល់ក្រុមគ្រីស្តទូតក្នុងបុណ្យទីហាសិបតាមព្រះបន្ទូលសន្យា មុនចាត់គេឲ្យចេញទៅប្រកាសដំណឹងល្អអំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ទៅដល់មនុស្សគ្រប់ជាតិសាសនលើផែនដីទាំងមូល។



ថតដោយ សម្បត្តិ

លោក ឃឹម សាខន ជាបេក្ខជនទទួលអគ្គសញ្ញាលាបថ្ងាសម្នាក់បានឲ្យដឹងថា "អគ្គសញ្ញាលាបថ្ងាសនេះ គឺបានធ្វើឲ្យខ្ញុំពោរពេញទៅដោយព្រះវិញ្ញាណ ដោយបំផុសគំនិតខ្ញុំថ្មីៗឲ្យរក្សាជំនឿឲ្យខ្ជាប់ខ្ជួន កុំឲ្យប្រាសចាកពីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់"។ លោកបានបន្តថា លោកនឹងបន្តប្រកាសដំណឹងល្អដល់អ្នកជិតខាងឲ្យពួកគេទទួលជឿលើព្រះយេស៊ូគ្រីស្ត ដោយបង្ហាញសេចក្តីស្រឡាញ់ និងយកចិត្តទុកដាក់ជួយអ្នកដទៃ។

តាមជំនឿនៃព្រះសហគមន៍កាតូលិក អស់អ្នកដែលទទួលអគ្គសញ្ញាលាបថ្ងាស គឺអស់អ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹករួចហើយ។ អគ្គសញ្ញានេះ គឺបញ្ជាក់បន្ថែមថា បងប្អូនជាគ្រីស្តបរិស័ទពេញលក្ខណៈ ។ ព្រះជាម្ចាស់ត្រាស់ហៅ គេឲ្យទទួលព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីបញ្ជាក់ជំនឿរបស់ខ្លួន និងចាត់ឲ្យបងប្អូនចេញទៅ ប្រកាសដំណឹងល្អអំពីព្រះយេស៊ូ តាមរយៈការធ្វើសក្ខីភាពអំពីជំនឿរបស់ខ្លួន ធ្វើជាសាក្សីនៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដល់មនុស្សដែលនៅជុំវិញយើង។

*ដោយ ដាលីស*




ថតដោយ សម្បត្តិ

Messenger -103.indd 12 6/22/2017 5:27:49 PM

# សម្តេចតេជោ ជួបសំណេះសំណាលជាមួយគ្រីស្តបរិសទ័នៅកម្ពុជា



ថតដោយ សុធីរិទ្ធិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា ទទួលជួបពិភាក្សាជាមួយគ្រីស្តបរិស័ទនៅក្នុងប្រទេសកម្ពុជាជាង៤០០០ នាក់ កាលពីថ្ងៃទី២៥ ឧសភា ២០១៧ នៅសាលសន្និបាត និងពិព័ណ៌កោះពេជ្រ រាជធានីភ្នំពេញ។

នេះជាលើកទី២ហើយ ដែលសម្តេចតេជោ ទទួលជួបពិភាក្សាជាមួយនឹងគ្រីស្តបរិសទ័នៅក្នុងប្រទេសកម្ពុជា ដែលពេលលើកទី១ ត្រូវបានប្រារព្ធក្នុងឆ្នាំ២០១៦។

ថ្លែងក្នុងឱកាសនេះ សម្តេចតេជោ បានអះអាងជាថ្មីម្តងទៀតនូវ សុខដុមនីយភាពខាងសាសនាក្នុងប្រទេសកម្ពុជា និងមានភាពល្អប្រសើរក្នុងទំនាក់ទំនង រវាងសាសនាព្រះពុទ្ធសាសនា អ៊ីស្លាមសាសនា គ្រីស្តសាសនាដែលពិតជាមានសារៈសំខាន់បំផុតក្នុងសុខុដុមភាពខាងសាសនា នេះដែលកម្ពុជាពុំមានជម្លោះសាសនាដូចបណ្តារប្រទេសដទៃទៀតនៅលើពិភពលោក។

សម្តេចតេជោ ក៏បានធ្វើការថ្លែងអំណរគុណ ចំពោះសហគមន៍គ្រីស្តដែលបានជំរុញនូវការអភិវឌ្ឍ និងសកម្មភាពមនុស្សធម៌ក្នុងប្រទេសកម្ពុជាផងដែរ។

យោងតាមក្រសួងធម្មការ និងសាសនាកម្ពុជាមាននិកាយចំនួន២ នៃសាសនាគ្រីស្ត ដូចជា កាតូលិក និងប្រូតេស្តង់។ អ្នកគោរពប្រតិបត្តិតាមនិកាយកាតូលិកមានចំនួន ១២៩០០នាក់ និងប្រូតេស្តង់ មានចំនួន ៨៣០៨៦ នាក់។

គ្រីស្តសាសនានិកាយកាតូលិកបានមានវត្តមាននៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ១៥៥៥។ នេះបើយោងតាមសៀវភៅប្រវត្តិសាស្ត្ររបស់ព្រះសហគមន៍កាតូលិក។

ប្រទេសកម្ពុជាត្រូវបានទទួលស្គាល់នូវសេរីភាពខាងជំនឿនិងសាសនា ខណៈពេលដែលសាសនា ព្រះពុទ្ធជាសាសនារបស់រដ្ឋ។ ៩៥ភាគរយនៃ ចំនួនប្រជាជនសរុបចំនួន១៥លាននាក់គោរពប្រតិបត្តិនូវសាសនាព្រះពុទ្ធ ដែលមាន ៤៥១៤ វត្តអារាមទូទាំងប្រទេស និង៥៦៨២០ ព្រះសង្ឃ ព្រមទាំងសាសនិកអ៊ីស្លាម ចំនួន ៣០០ ០០០ នាក់៕

*ដោយ ផល សុផានិត*

# ព្រះសហគមន៍ភូមិភាគភ្នំពេញយកចិត្តទុកដាក់យ៉ាងខ្លាំងអំពីសិទ្ធិកុមារ

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានយកចិត្តទុកដាក់ចំពោះកុមារទាំងឡាយដោយចូលរួម និងគាំទ្រយ៉ាងពេញទំហឹង អំពីសិទ្ធិកុមារ។

ជាក់ស្តែងលោកអភិបាល អូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានដាក់ផែនការណ៍ឲ្យការិយាល័យយុវជន ជំទង់ និងកុមារនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ប្រារព្ធទិវាសិទ្ធិកុមារអន្តរជាតិ កាលពីថ្ងៃទី០១ មិថុនា ២០១៧ នៅគ្រប់ព្រះសហគមន៍នានានៅក្នុងភូមិភាគភ្នំពេញនេះ ដើម្បីឲ្យកុមារទាំងនោះទទួលបានអំណរសប្បាយជាមួយគ្នា ជាពិសេសទទួលបានការយល់ដឹង បន្ថែមអំពីសិទ្ធទាំងឡាយដែលពួកគេមាន។ ព្រមទាំងមានការអធិដ្ឋានជាពិសេសសម្រាប់កុមារទាំងឡាយនៅក្នុងពិភពលោក ដែលបានបាត់បង់ជីវិត និងកំពុងតែរងគ្រោះដោយការរំលោភបំពាន។ លោកអភិបាលអូលីវីយេបានចូលរួមដោយផ្ទាល់នៅតាមព្រះសហគមន៍កាតូលិកមណ្ឌលសកម្មភាពតាកែវ និងព្រះសហគមន៍កាតូលិកមណ្ឌលសកម្មភាពកំពត។

លោកស៊ាន់ សារឿន អ្នកសម្របសម្រួលនៅក្នុងកម្មវិធីនេះទាំងមូលបានឲ្យដឹងថា នេះជាលើកទីមួយ ដែលព្រះសហគមន៍បានរៀបចំកម្មវិធីនេះជាមួយកុមារព្រមៗគ្នា ទៅតាមព្រះសហគមន៍នីមួយៗគ្រប់កន្លែងមណ្ឌលសកម្មភាពនៃភូមិភាគភ្នំពេញ។ លោកពិតជាមានអំណរសប្បាយដោយបានឃើញកុមារទាំងនោះមានស្នាមញញឹមគ្រប់ៗគ្នា ហើយកម្មវិធីបានប្រព្រឹត្តទៅយ៉ាងរលូន។

លោកបូជាចារ្យ ដាមីញ៉ាំង ហ្វានីរ ដែលទទួលខុសត្រូវមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង បានមានប្រសាសន៍ថា កម្មវិធីនេះមានសារៈសំខាន់ខ្លាំងណាស់។ កុមារដែលបានចូលរួមគឺមានទាំងកុមារជាគ្រីស្តបរិស័ទ និងមិនមែនជាគ្រីស្តបរិស័ទ។ លោកបន្តថា ក្មេងៗសំខាន់ ព្រោះព្រះយេស៊ូមានព្រះបន្ទូលថា ប្រសិនបើអ្នកគ្មានចិត្តដូចកូនក្មេង អ្នកមិនអាចចូលស្ថានបរមសុខបានទេ។ លោកដាមីញ៉ាំងក៏បានបកស្រាយផងដែរថា ក្មេងៗជាមនុស្សសាមញ្ញ មានអំណរសប្បាយ និងនាំឲ្យមនុស្សធំចូលរួមនៅក្នុងអំណរសប្បាយ ហើយចំពោះសង្គមវិញ ពួកគេគឺជាអនាគតនៃសង្គម ដូចនេះសម្រាប់ប្រទេសនីមួយៗគឺត្រូវជួយឲ្យកុមារទាំងនោះ បានរីកចម្រើនដោយចេះទទួលខុសត្រូវ និងយល់អំពីសិទ្ធិរបស់ពួកគាត់ផងដែរ។

ជាលទ្ធផលព្រះសហគមន៍ជាង ៤០ កន្លែង នៃមណ្ឌលសកម្មភាពទាំង៩របស់ភូមិភាគភ្នំពេញបានរៀបចំកម្មវិធីខាងលើជាមួយកុមារជាង៤០០០នាក់។ កុមារទាំងអស់នោះបានទទួលការយល់ដឹងអំពីសិទ្ធធំៗទាំង៤របស់ពួកគេគឺ សិទ្ធិរស់រានមានជីវិត សិទ្ធិក្នុងការអភិវឌ្ឍ សិទ្ធិទទួលបាននូវការការពារ និងសិទ្ធិចូលរួម។ *ដោយ ដាលីស*


ថតដោយ សុធីរិទ្ធិ

# សម្តេចប៉ាបប្រកាសតែងតាំងកាឌីណាល់ថ្មីចំនួន៥រូប



លោកអភិបាល លូវីស ម៉ារីលីង នៅព្រះសហគមន៍កាតូលិកភូមិភាគ ប៉ាកសេ នៃប្រទេសឡាវ

ទីភ្នាក់ងារព័ត៌មានកាតូលិកបានរាយការណ៍ថា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃអាទិត្យ បានកំណត់យកថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ គឺជាថ្ងៃនៃការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាកាឌីណាល់ថ្មីមួយ។

ប្រភពដដែលបានរាយការណ៍ឲ្យដឹងថា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ គ្រោងយកថ្ងៃនៃការរៀបចំកិច្ចប្រជុំនោះ ប្រកាសតែងតាំងកាឌីណាល់ថ្មីចំនួន៥រូប បន្ថែមដើម្បីជួយមើលកិច្ចការព្រះសហគមន៍កាតូលិកបន្ថែមទៀត។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា "បងប្អូនជាទីស្រឡាញ់ ខ្ញុំសូមប្រកាសប្រាប់អស់លោកទាំងអស់គ្នាថា កាលពីថ្ងៃទី២៨ ខែមិថុនា ខ្ញុំនឹងរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាកាឌីណាល់មួយ សម្រាប់តែងតាំងកាឌីណាល់ថ្មីចំនួន៥រូប"។

ប្រភពដដែលបានបន្តថា បើតាមសម្តេចប៉ាប កាឌីណាល់ថ្មីទាំង៥ រូបនេះ គឺមកពីទីកន្លែងផ្សេងៗនៃពិភពលោក ដើម្បីជួយបម្រើព្រះសហគមន៍នៅក្នុងការប្រកាសដំណឹងល្អ។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូបានថ្លែងបន្តថា នៅថ្ងៃទី២៩ ខែមិថុនា នៅទីលានសន្តសិលា និងសន្តប៉ូល កាឌីណាល់ថ្មី នឹងរៀបចំពិធីថ្វាយអភិបូជារួមគ្នាជាមួយនឹងសម្តេចប៉ាបផ្ទាល់។

កាឌីណាលើថ្មីទាំង៥ រូបគឺ ត្រូវបានគេដឹងថា មានមួយរូបជាអភិបាលព្រះសហ-គមន៍កាតូលិកភូមិភាគប៉ាកសេនៃប្រទេសឡាវ គឺលោកអភិបាល លូវីស ម៉ារីលីង។ លោកក៏ជាអនុប្រធាន នៃសភាលោកអភិបាលឡាវកម្ពុជាបច្ចុប្បន្ន។

លោកអភិបាល លូវីស ម៉ារី លីង ប្រសូតនៅថ្ងៃទី៨ មេសា ១៩៤៤។ លោកទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យក្នុងឆ្នាំ១៩៧២ ហើយទទួល អគ្គសញ្ញាតែងតាំងជាអភិបាលក្នុងឆ្នាំ២០០០។ លោកជាអភិបាលនៃភូមិភាគ ប៉ាសេ ក្នុងឆ្នាំ២០០១។ ចាប់ពីខែកុម្ភៈ ឆ្នាំ២០១៧ មកលោកទទួលមើលការថែរក្សា ភូមិភាគវៀងចន្ទ ផងដែរស្របពេលដែល លោកអភិបាលនៃភូមិនេះត្រូវចូលនិវត្តន៍។

សូមបញ្ជាក់ថា កាលពីខែធ្នូ ឆ្នាំ២០១៦ កន្លងទៅនេះព្រះសហគមន៍កាតូលិកបានប្រកាសទទួលស្គាល់មរណសាក្សីនៅប្រទេសឡាវមួយចំនួនថា ជាអ្នកមានសុភ-មង្គលដ៏ពេលលេញ។ ក្នុងចំណោម មរណសាក្សីទាំងនោះក៏មាន បងប្អូនជីដូនមួយរបស់លោកកាឌីណាល់ថ្មី លូវីស ម៉ារី លីងផងដែរ។

# លោកអភិបាល អូលីវីយេ ជំរុញឲ្យមាតាបិតាយកចិត្តទុកដាក់លើការសិក្សារបស់កូន

ថ្លែងនៅក្នុងធម្មទេសនាទៅកាន់គ្រីស្តបរិស័ទជាច្រើនរយនាក់ នាឱកាសបុណ្យព្រះយេស៊ូយាងឡើងស្ថានបរមសុខ និងសម្ពោធអាគារសិក្សាថ្មី នៅព្រះវិហារសន្តីម៉ារី ទួលតាំង កាលពីថ្ងៃទី២៨ ឧសភានេះ លោកអូលីវីយេ អភិបាលព្រះសហគមន៍ភូមិភ្នំពេញបានជំរុញឲ្យមាតាបិតានៅតាមព្រះសហគមន៍កាតូលិកនានាក្នុងភូមិភាគភ្នំពេញ យកចិត្តទុកដាក់បញ្ជូនកូនឲ្យទៅសាលា ជាជាងឲ្យកូនទៅជួយធ្វើការរកស៊ី។

លោកអភិបាលអូលីវីយេ បានមានប្រសាសន៍ថា "នៅតាមដងទន្លេមេគង្គ និងបាសាក់មានបងប្អូនគ្រីស្តបរិស័ទច្រើនណាស់ដែលរស់នៅ តាំងពីមុនសង្គ្រាម និងក្រោយសង្គ្រាមរហូតបច្ចុប្បន្ន។ លោកបន្តថា នៅក្នុងព្រះសហគមន៍ យើងគិតថានឹងខិតខំរស់នៅជាគ្រួសារតែមួយតាមព្រះជាយេស៊ូ ហើយ១៥ព្រះសហគមន៍កាតូលិកនៅតាមដងទន្លេនេះ ខ្ញុំបានបង្កើតសាលាមត្តេយ្យ និងបឋមសិក្សាឲ្យកុមារតូចរៀនរហូតដល់ថ្នាក់ទី២ ឬទី៣ ដើម្បីឲ្យគេមានមូលដ្ឋានមុន ពួកគេ ចូលទៅរៀននៅសាលារដ្ឋបាន"។

ដាក់ស្តែងណាស់ការខិតខំប្រឹងប្រែងនិងយកចិត្តទុកដាក់របស់លោកអភិបាលអូលីវីយេ នាំឲ្យព្រះសហគមន៍សន្តីម៉ារីនេះបើកថ្នាក់សិក្សាមូលដ្ឋានសម្រាប់កុមារ ពីកំរិតមត្តេយ្យ ដល់បឋមសិក្សា ថ្នាក់ទី១ ទី២ជាដើម។ ពេលនេះក៏បានកសាងអាគារដ៏ស្កឹមស្កៃ សម្រាប់បម្រើក្នុងវិស័យអប់រំទូទៅនេះផងដែរ។

បន្ទាប់ពីអភិបូជា លោកអភិបាលអូលីវីយេរួមជាមួយលោកអភិបាល លោកបូជាចារ្យ និងសប្បុរសជនដែលបានឧបត្ថម្ភ ក្នុងការសាងសង់ បានអញ្ជើញកាត់ខ្សែបូរសម្ពោធដាក់ឲ្យប្រើប្រាស់អាគារសិក្សាជាផ្លូវការ។ លោកអភិបាលក៏បានបាចទឹកព្រះពរ នៅក្នុងអគារថ្មីទាំងមូលដើម្បីព្រះជាម្ចាស់ថែរក្សាគ្រប់មនុស្សទាំងអស់ដែលស្នាក់នៅ និងចេញចូលក្នុងអាគារនេះ។

អាគារថ្មីនេះមានសប្បុរសជនជាច្រើនបានជួយឧបត្ថម្ភ រួមទាំងលោកអគ្គរាជទូតប៊ុរីវ៉ាទីកង់ ប្រចាំប្រទេសវៀតណាមផងដែរ។

*ដោយ ដាលីស*



ថតដោយ សុធីរិទ្ធិ

# លោកឈឿង ជុន(១៩៤៣-១៩៧៥)

## Mr. CHOEUNG CHUN

## គ្រហស្ថនិងជាគ្រូអប់រំជំនឿ



គាត់កើតប្រហែលជាឆ្នាំ១៩៤៣ ស្រុកកំណើតនៅកំពង់គោ។ ជាកូនរបស់តាជឹងនិងយាយសុន អ្នកស្រុកកំពង់គ។ មានបងប្អូន ៥ នាក់ ជាកូនច្បង។ លោករៀនសូត្រដូចក្មេងទូទៅនៅកំពង់គោ។

ឆ្នាំ ១៩៦១-១៩៦៥ ត្រូវជ្រើសរើសពីលោកពុកវីណេ(MEP)ទៅរៀនគ្រូអប់រំជំនឿនៅបាត់ដំបង ដើម្បីរៀបចំជាគ្រូអប់រំជំនឿជាមួយក្រុមគ្រូមួយចំនួន មានដូចជាលោកម៉ម សារ៉ូ និង លោកថោងជាដើម។ លោករៀនជាមួយលោកពុកកូអេឡង់ និងលោកផ្ទារ សាឡាស់។ លោករៀបការនៅ ឆ្នាំ ១៩៦៥។

ពេលគាត់មកវិញបង្រៀនអក្សរនិងអប់រំជំនឿ តាមថ្នាក់របស់ក្មេង។ ក្នុងមួយអាទិត្យមានបង្រៀនពីរដងក្រៅពីថ្ងៃនេះ គឺរៀនអក្សរ។លោកមានចរិតល្អ ស្លូតបូតមានចិត្តតស៊ូ។លោកជាគំរូសម្រាប់កូនសិស្ស។

ឆ្នាំ ១៩៧០ សកម្មភាពបង្រៀនត្រូវឈប់ ព្រោះសង្គ្រាមចាប់ផ្តើមផ្ទុះ។ ពួកទាហានវៀតកុង ចាប់លោកពុកវីណេយកទៅព្រៃ ក្រោយមក លោកពុកត្រូវទាហានសាធារណរដ្ឋចាប់ទៅភ្នំពេញ។

ឆ្នាំ១៩៧២ ជាឆ្នាំដែលខ្មែរក្រហម វាយយកភូមិកំពង់គោ។ លោកត្រូវជម្លៀសទៅតាមអ្នកភូមិ ដំបូងត្រូវខ្មែរក្រហម កៀរទៅតំបន់ស្ទោង។ ក្រោយមក នៅឆ្នាំ ១៩៧៥ ទាហានខ្មែរក្រហមបានប្រាប់ឲ្យមនុស្សប្រុសថា នឹងយកទៅរៀន ដោយចងខ្សែដើរតៗគ្នា ប៉ុន្តែការពិតគឺគេយកទៅសម្លាប់។

ដូច្នេះ យើងជឿថា លោកត្រូវគេសម្លាប់ ជាមួយតាឈឿង ឪពុករបស់លោកនៅស្ទោង នៅឆ្នាំ ១៩៧៥។

---



សន្ត យ៉ូហាន ម៉ារីវិយ៉ាណៃ

លោកយ៉ូហាន ម៉ារី កើតនៅប្រទេសបារាំង នៅឆ្នាំ១៧៨៦។ កាលគាត់នៅក្មេង គាត់ ធ្វើការនៅក្នុងកសិដ្ឋានរបស់ឪពុកគាត់។ នៅពេលគាត់ត្រឡប់មកពីការងារវិញ គាត់បង្រៀនក្មេងៗឲ្យចេះអធិដ្ឋាន និងឲ្យគេស្គាល់ព្រះយេស៊ូ។ លោកយ៉ូហាន ម៉ារី រៀន មិនសូវពូកែ តែមានលោកបូជាចារ្យម្នាក់ជួយឲ្យគាត់ចូលទៅរៀននៅក្នុងទេវវិទ្យាល័យ។ យូរឆ្នាំក្រោយមក ក្រោយពីបានខិតខំរៀនអស់ពីសមត្ថភាព លោកយ៉ូហាន ម៉ារី ក្លាយទៅជាបូជាចារ្យ។ គេបញ្ជូនគាត់ទៅក្នុងព្រះសហគមន៍ដ៏តូចមួយ នៅភូមិអាស។ ដោយ សារគ្មាននរណាម្នាក់ទៅព្រះវិហារទេ លោកឪពុកយ៉ូហាន ម៉ារី ទៅសួរសុខទុក្ខគេនៅតាមផ្ទះ។ ជាចុងក្រោយ មនុស្សជាច្រើនបានទៅព្រះវិហារចូលរួមអភិបូជា។ ជារៀង រាល់ព្រឹក គាត់តាំងព្រះកាយ និងអធិដ្ឋានជាច្រើនម៉ោង។ គាត់រស់នៅដូចជាអ្នកក្រីក្របំផុត និងតមអាហារជាញឹកញាប់។ ព្រះវិញ្ញាណដ៏វិសុទ្ធបានប្រោសប្រទាន ព្រះអំណោយទានដ៏ពិសេសដល់គាត់ គឺគាត់ពូកែសម្រុះសម្រួលមនុស្សបាប ជាមួយព្រះជាម្ចាស់ និងជួយទូន្មានពួកគេឲ្យទៅធ្វើជាគ្រីស្តបរិស័ទដ៏ល្អ។ គាត់ចំណាយពេលអស់ជាច្រើន ដោយធ្វើអគ្គសញ្ញាលើកលែងទោស។ គាត់ធ្លាប់និយាយថា រាល់អំពើបាបរបស់យើង ដូចជាតំណក់ទឹកនៅក្នុងមហាសមុទ្រនៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ លោកឪពុកយ៉ូហាន ម៉ារី ជួយណែនាំព្រះសហគមន៍នៅភូមិអាស អស់រយៈពេល៤០ឆ្នាំ ហើយ ទទួលមរណភាពនៅពេលអាយុ ៧៣ឆ្នាំ។ គាត់ជាគំរូសម្រាប់លោកបូជាចារ្យទាំងអស់។

---

# ច្បាប់ចរាចរណ៍ ផ្លូវគោកថ្មី

**មាត្រាទី ៣៥៖**

ក្នុងករណីមានគ្រោះថ្នាក់ចរាចរណ៍ ភាគីពាក់ព័ន្ធនឹងគ្រោះថ្នាក់ត្រូវអនុវត្តដូចខាងក្រោម៖

១- បញ្ឈប់យានរបស់ខ្លួនជាបន្ទាន់ ដោយមិនធ្វើឲ្យរំខាន ឬបង្កឲ្យមានគ្រោះថ្នាក់ដល់អ្នកដទៃទៀត។

២- មិនត្រូវធ្វើឲ្យមានការប្រែប្រួលដល់ទីកន្លែងកើតហេតុ ឬឲ្យបាត់ដាន ឬស្នាម ដែលជាកត្តាមានប្រយោជន៍ដល់ការស្វែងរកអ្នកទទួលខុសត្រូវក្នុងរឿងគ្រោះថ្នាក់។

៣- ជូនដំណឹងជាបន្ទាន់ទៅអាជ្ញាធរដែនដី ឬនគរបាលចរាចរណ៍ផ្លូវគោកនៅជិតបំផុត។

៤- មិនត្រូវប្រើហិង្សា ឬបង្កជម្លោះរវាងភាគីពាក់ព័ន្ធ។

៥- មិនត្រូវចាកចេញពីកន្លែងកើតហេតុមុនការព្រមព្រៀងគ្នា ឬដោយគ្មានការអនុញ្ញាតពីនគរបាលចរាចរណ៍ផ្លូវគោក។

ចំពោះអ្នកឃើញហេតុការណ៍ ត្រូវជូនដំណឹងជាបន្ទាន់ទៅអាជ្ញាធរដែនដី ឬនគរបាលចរាចរណ៍ផ្លូវគោកនៅជិតបំផុត។

មាត្រាទី ៣៦៖

បើគ្រោះថ្នាក់កើតឡើងបណ្តាលឲ្យខូចខាតតែទ្រព្យសម្បត្តិ ភាគីទាំងពីរ អាចសម្រួលគ្នាបានដោយមិនចាំបាច់សុំអន្តរាគមន៍ពីមន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកឡើយ។

**មាត្រាទី ៣៧៖**

ក្នុងករណីមានមនុស្សរងរបួស ឬបាត់បង់ជីវិត អ្នកបើកបរ ឬអ្នកប្រើប្រាស់ផ្លូវគ្រប់រូបដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់ ឬអ្នកឃើញហេតុការណ៍នេះ ត្រូវចាត់ចែងជូនព័ត៌មានទៅអាជ្ញាធរដែនដី ឬនគរបាលចរាចរណ៍ផ្លូវគោក ឬបញ្ជូនជនរងគ្រោះជាបន្ទាន់ទៅមន្ទីរពេទ្យដែលនៅជិតកន្លែងកើតហេតុបំផុត។

**មាត្រាទី ៣៨៖**

ចំពោះគ្រោះថ្នាក់ចរាចរណ៍ដែលភាគីម្ខាងជាភ្នាក់ងារទូត ឬបេសកកម្មទូត នគរបាលចរាចរណ៍ផ្លូវគោកត្រូវចម្លងកំណត់ហេតុ និងធ្វើរបាយការណ៍ស្តីពីគ្រោះថ្នាក់នេះផ្ញើទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីចាត់ចែងឲ្យអ្នកតំណាងមកចូលរួមសហការជាមួយនគរបាលចរាចរណ៍ផ្លូវគោកដើម្បីពិនិត្យ និងលើកវិធានការសមស្រប។

Messenger -103.indd 15 6/22/2017 5:28:01 PM

# លោកបូជាចារ្យ យ៉ូហាន យេស៊ូ សាឡាសាណូ នឹងចាកចេញពីកម្ពុជាចុងខែមិថុនានេះ



**លោកបូជាចារ្យ យ៉ូហាន យេស៊ូ សាឡាសាណូ**

បើនិយាយអំពីលោកបូជាចារ្យយ៉ូហាន យេស៊ូ សាឡាសាណូ មិនសូវស្គាល់ទេ តែបើនិយាយអំពីលោកឪពុកហ៊ាន់ គឺពិតណាស់មានគ្រីស្តបរិស័ទកាតូលិកជាច្រើនបានស្គាល់។ លោកគឺជាបូជាចារ្យនៃក្រុមសាសនទូតយេរ៉ូម៉ាល់។ លោកបានមកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៧ លោកបម្រើនៅព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។ ប៉ុន្មានឆ្នាំចុងក្រោយនេះ លោកបម្រើនៅព្រះសហគមន៍កាតូលិកមណ្ឌលគិរី។

លោកអន់តូនីសាមី ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម បានចាត់លោកឲ្យទៅបំពេញបេសកកម្មនៅខេត្តមណ្ឌលគិរី ក្នុងឆ្នាំ២០០៩។ នៅក្នុងមុខងារអ្នកប្រកាសដំណឹងល្អ និងជាអ្នកថែរក្សាជំនឿកាតូលិក លោកបានខិតខំអស់ពីកម្លាំងកាយចិត្ត យកចិត្តទុកដាក់អប់រំជំនឿ និងកសាងជីវិតថ្មីសម្រាប់បងប្អូនគ្រីស្តបរិស័ទនៅក្នុងខេត្តនេះផង។ គ្រីស្តបរិស័ទក្នុងខេត្តមណ្ឌលគិរី សុទ្ធតែជាជនជាតិដើមភាគតិចពូណង។ មានកំរិតជីវភាពទាប ការអប់រំក៏នៅមានកំរិតទាបដែរ។

តាមសក្ខីភាពរបស់គណៈកម្មការព្រះសហគមន៍កាតូលិកប៊ូស្រា ដែលអ្នកនាំសារទទួលបាន រៀបរាប់ពីគុណសម្បត្តិរបស់លោកបូជាចារ្យ ហ៊ាន់យ៉ាងនេះថា ពេលលោកមកថែរក្សាបងប្អូនគ្រីស្តបរិស័ទព្រះសហគមន៍ប៊ូស្រា លោកបានខិតខំមានទំនាក់ទំនងជាមួយគេ។ លោកខិតខំរៀនភាសាពូណង ដើម្បីងាយស្រួលក្នុងការទាក់ទងជាមួយគ្រីស្តបរិស័ទ។

លិខិតបានរៀបរាប់បន្តថា លោកបានយកចិត្តទុកដាក់ សួរសុខទុក្ខគេ និងអធិដ្ឋានដល់អ្នកជំងឺ បញ្ជូនអ្នកជំងឺទៅព្យាបាលនៅតាមមន្ទីរពេទ្យនានា។ លោកតែងតែចូលរួមរំលែកទុក្ខបងប្អូនពេលមានសមាជិកទទួលមរណភាព ចូលរួមក្នុងពិធីបញ្ចុះសព។ ទៅអធិដ្ឋាននៅតាមផ្ទះពេលបុណ្យភ្ជុំ ទៅអធិដ្ឋានតាមចំការពេលរដូវធ្វើចំការ ទោះបីជិត ឬឆ្ងាយ។

អំពីវិស័យអប់រំ លោកបានកសាងអាគារបើកមត្តេយ្យសិក្សា និងបើកថ្នាក់សម្រាប់បង្រៀនគួរបន្ថែមដល់សិស្សានុសិស្សកំរិតមធ្យម។ លើសនេះ ជារៀងរាល់ឆ្នាំលោកបានជ្រើសរើសយុវជនយុវនារីជាច្រើននាក់ឲ្យបានចូលរៀននៅមូលដ្ឋាន និងបន្តការសិក្សាឲ្យបានកាន់ខ្ពស់ គឺបានបញ្ជូនឲ្យរៀនបន្តនៅខេត្តកំពង់ចាម ក្រុងភ្នំពេញ ខេត្តព្រៃវែង ខេត្តស្វាយរៀង ក្រុងសែនមនោរម្យជាដើម។ លោកក៏បានកសាងមណ្ឌលមួយសម្រាប់សិស្សស្នាក់នៅដើម្បីបន្តការសិក្សាដែលមាននៅទីរួមខេត្តមណ្ឌលគិរី។

អំពីការអប់រំជំនឿវិញគណៈកម្មការព្រះសហគមន៍បានរៀបរាប់ថា លោកបានខិតខំអប់រំណែនាំបងប្អូនគ្រីស្តបរិស័ទឲ្យកែប្រែចិត្តគំនិត ឲ្យរស់នៅតាមរបៀបព្រះយេស៊ូ។ រំលឹកគេឲ្យខិតខំចូលរួមអធិដ្ឋានជាមួយគ្នា ចូលរួមអភិបូជាយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូល និងព្យាយាមអានព្រះគម្ពីរដោយខ្លួនឯង ចេះស្រឡាញ់គ្នានិងគោរពគ្នាទៅវិញទៅមក។ ឲ្យយកចិត្តទុកដាក់ថែរក្សាវប្បធម៌ ប្រពៃណីទំនៀមទំលាប់របស់បងប្អូនជនជាតិដើមភាគតិចពូណង មានចម្រៀងសរសើរតម្កើងព្រះជាម្ចាស់ និងព្រះគម្ពីរជាភាសាពូណង។

ចំពោះគ្រួសារកាតូលិក លោកបានណែនាំឲ្យមាតាបិតាទាំងអស់ឲ្យធ្វើជាគំរូដល់កូនៗ ដែលនឹងក្លាយទៅជាសរសរទ្រូងនៃគ្រួសារ សហគមន៍ ព្រះសហគមន៍ សង្គម និងប្រទេសជាតិ។

យុវនារី កឹត ជាយុវនារីជាតិ ពូណង ដែលលោកបានលើកទឹកចិត្ត និងជំរុញឲ្យរៀន បន្តនៅភ្នំពេញ បានថ្លែងអំណរគុណលោកឪពុកហ៊ាន់ដែលបម្រើនៅព្រះសហគមន៍ខេត្តមណ្ឌលគិរី។ ជួយយុវជនកុមារាកុមារី និងគ្រីស្តបរិស័ទ ជាពិសេសគឺរូបនាងផ្ទាល់ ឲ្យបានបន្តការសិក្សានៅភ្នំពេញ លើមុខវិជ្ជាពេទ្យធ្មេញ។

ចំណែកយុវជនរ៉ាណឺប ដែលបន្តរៀនថ្នាក់វិទ្យាល័យនៅភ្នំពេញដែរនោះក៏បានអរគុណដល់លោកបូជាចារ្យដែលបានផ្តល់ឱកាសឲ្យរូបគេបន្តការសិក្សា និងបានណែនាំអប់រំឲ្យគេមានការរីកចម្រើនអំពីជីវិតផ្លូវវិញ្ញាណ នាំគេមានជំនឿរឹងមាំ។

រីឯកញ្ញាប្រេង ហៀវ ជាមិត្តភក្តិរបស់កញ្ញាកឹត បានថ្លែងថា នាងអរគុណលោកឪពុកហ៊ាន់ ដែលបានណែនាំព្រះសហគមន៍នៅភូមិរបស់នាង។ ហៀវបន្តថា ក្នុងបេសកកម្ម នាងសង្កេតឃើញថា លោកបូជាចារ្យហត់ខ្លាំងណាស់។ ប៉ុន្តែលោកបង្ហាញនូវអំណរសប្បាយ រីករាយពោរពេញដោយកម្លាំង ដែលជាគំរូសម្រាប់នាងជានិច្ច។

លោកបូជាចារ្យយ៉ូហាន យេស៊ូ សាឡាសាណូ នឹងទទួលមុខការថ្មី ដែលប្រធានក្រុមសាសនទូត យេរ៉ូម៉ាល់ បានប្រគល់ឲ្យគឺបំពេញបេសកកម្មនៅសហរដ្ឋអាមេរិក។ ក្រុមសាសនទូតយេរ៉ូម៉ាល់ មានបូជាចារ្យចំនួន៥រូប កំពុងបម្រើព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាគឺ ២រូប នៅព្រះសហគមន៍ភូមិបាត់ដំបង ២រូបនៅព្រះសហគមន៍ភូមិភាគភ្នំពេញ និងមួយរូបបម្រើព្រះសហគមន៍ភូមិភាគកំពង់ចាម។



# មេក្រុមយុវជនភូមិភាគភ្នំពេញជួបជុំគ្នារិះគិតអំពីភាពជាអ្នកដឹកនាំ

ក្រុមការិយាល័យ យុវជន ជំទង់ និង កុមារ នៃព្រះសហគមន៍កាតូលិកភូមិភាគ ភ្នំពេញ បានរៀបចំសិក្ខាសាលា សម្រាប់ ប្រធាន និងអនុប្រធានយុវជនរបស់ព្រះ សហគមន៍នីមួយៗក្នុងភូមិភាគ ក្រោម ប្រធានបទ "ភាពជាអ្នកដឹកនាំដែលកសាង ទំនុកចិត្តក្នុងក្រុម"។ កម្មវិធីសិក្ខាសាលា នេះ បានធ្វើឡើងនៅព្រះសហគមន៍សន្តី តេរេសាព្រែកប្បាស់ កាលពីថ្ងៃទី១៩ ដល់ ថ្ងៃទី២១ខែឧសភា ឆ្នាំ២០១៧ ដោយ មានលោកអភិបាល អូលីវីយេ និងក្រុម ការងារនៃការិយាល័យយុវជន ជំទង់ និង កុមារ ជាអ្នកណែនាំ និងមានសិក្ខាកាម ប្រមាណជា៥០នាក់ ដែលមកពីព្រះ សហគមន៍នីមួយៗក្នុងភូមិភាគភ្នំពេញ។

ថ្លែងក្នុងកម្មវិធីបិទសិក្ខាសាលានោះ លោកអភិបាល អីលីវីយេ មានប្រសាសន៍ ថា ចាប់ពីខែកញ្ញា ឆ្នាំ២០១៧នេះ ព្រះ សហគមន៍នឹងរិះគិតអំពីក្រុមគ្រួសារ ហើយ នឹងមានរៀបចំកម្មវិធីពិសេសសម្រាប់យុវ-ជន ដើម្បីត្រៀមខ្លួនរិះគិតអំពីគ្រួសារក្នុង មួយឆ្នាំពីរដងតាមមណ្ឌលនីមួយៗ និង មួយខែម្តងឲ្យយុវជនតាមកន្លែងនីមួយៗ រិះគិតរួមជាមួយគ្នាដោយមានឯកសារខ្លះៗ មានអត្ថបទព្រះគម្ពីរ ប្រធានបទផ្សេងៗ និងសំណួរនានាទាក់ទងនឹងសង្គម ជីវិត យុវវ័យ សុខភាព និងកម្មវិធីផ្សេងៗ ដោយ ទទួលពន្លឺពីព្រះគម្ពីរ។

លោកអភិបាល ក៏បានសុំឲ្យយុវជន យុវនារីខិតខំសហការគ្នាជាមួយប្រទេស ឡាវ ព្រោះព្រះសហគមន៍ទាំងពីរ គឺទាំង ប្រទេសឡាវ និងប្រទេសកម្ពុជា មាន ក្រុមលោកអភិបាលតែមួយ ហើយព្រះ សហគមន៍នឹងរៀបចំឲ្យមានទិវាយុវជន ឡាវ-កម្ពុជាម្តងទៀតក្នុងឆ្នាំ២០១៨នៅ ប្រទេសឡាវ។ លោកអភិបាល ក៏បាន បន្តថា ក្រុមយុវជនត្រូវការគិត តើក្រុម យុវជនផ្តល់សក្ខីភាពអ្វីខ្លះដើម្បីឲ្យបងប្អូន ឯទៀតៗបានយល់ បានឃើញអំពីសេចក្តី សង្ឃឹមរបស់ខ្លួន? លោកអភិបាលសង្កត់ ធ្ងន់ថា យុវជនត្រូវតែបង្ហាញជាក់ស្តែងថា គ្រីស្តបរិស័ទជាព្រះសហគមន៍ដែលជា គ្រួសារមួយចេះស្រឡាញ់គ្នាទៅវិញទៅ មក។ លោកអភិបាលបានជំរុញឲ្យក្រុម យុវជនទាំងអស់ចូលរួមជាមួយគ្នាផ្តល់ សក្ខីភាពអំពីជំនឿក្នុងមួយខែម្តងដើម្បី ជួយដល់អ្នកដែលគ្មានទីពឹង និងគ្មាន សេចក្តីសង្ឃឹម ។

លោក ផុន សុផល ជាអ្នកសម្រប សម្រួលការិយាល័យយុវជន ជំទង់ និង កុមារភូមិភាគភ្នំពេញ មានប្រសាសន៍ថា យុវជនដែលបានចូលរួមសិក្ខាសាលនេះ បានរៀនច្រើន អំពីភាពជាអ្នកដឹកនាំ។ ហើយឆ្នាំនេះដែរ ការិយាល័យយុវជន ជំទង់ និងកុមារភូមិភាគភ្នំពេញ នឹងរៀបចំជា សៀវភៅមេរៀន ដែលមានទាំងមេរៀនតាម ប្រធានបទ និងមានទាំងព្រះគម្ពីរខ្លះៗ ដើម្បីឲ្យប្រធាន ឬអនុប្រធានក្រុមយុវជន ជួបជាមួយសមាជិកនៃក្រុមយុវជនតាម ព្រះសហគមន៍ រិះគិតទៅលើប្រធានបទ នីមួយៗដែលការិយាល័យបានរៀបចំ យ៉ាង តិចមួយខែម្តង។ លោកក៏បានបន្ថែមថា ចាប់ពីខែមិថុនា ឆ្នាំ២០១៧នេះ ក្រុម ការិយាល័យយុវជន ជំទង់ និងកុមារ នឹង រៀបចំសិក្ខាសាលា តាមព្រះសហគមន៍ នីមួយៗក្នុងភូមិភាគភ្នំពេញ ដើម្បីពង្រឹង សមត្ថភាព និងបង្កើននូវទំនាក់ទំនងល្អ ជាមួយយុវជន។



ថតដោយ សុធីរិទ្ធិ

យុវនារី ចរិយា មកពីព្រះសហគមន៍ ទួលក្រសាំង ក្នុងមណ្ឌលសកម្មភាព ទន្លេបាសាក់ មានចំណាប់អារម្មណ៍លើ សិក្ខាសាលានេះថា ក្រោយពីបានទទួល ការសិក្សារយៈពេលពីរថ្ងៃកន្លងមក គាត់ យល់ឃើញថាមណ្ឌលសកម្មភាពទន្លេ បាសាក់ នៅមានការខ្វះខាតច្រើនអំពីកម្ម វិធីជាមួយក្រុមយុវជន និងជំទង់នៅក្នុង មណ្ឌល។ ព្រោះថាព្រះសហគមន៍នីមួយៗ ក្នុងមណ្ឌលសកម្មភាពបាសាក់នៅឆ្ងាយ ពីគ្នា ដូច្នេះពិបាកក្នុងការជួបជុំគ្នារៀបចំ កម្មវិធីផ្សេង។ យុវនារីរូបនេះ ក៏បានបញ្ជាក់ ដែរថា នៅតាមព្រះសហគមន៍នីមួយៗ ក្រុម យុវជន និងជំទង់ ក៏បានជួបគ្នា សម្រាប់កម្ម វិធីអប់រំជំនឿ និងសំណាក់ធម៌ ពីរខែម្តង។ អ្វីដែលសំខាន់ ចរិយា ចង់ឲ្យមានការចង ក្រងជាក្រុមយុវជនតាមបណ្តាញផ្សព្វផ្សាយ សង្គមហ្វេសបុក ដើម្បីងាយស្រួលក្នុងការ ទទួលព័ត៌មាន ទទួលការអប់រំ ទទួលមេរៀន ទទួលកម្មវិធីថ្មីៗ រៀនពីគ្នាទៅវិញទៅមក និងដើម្បីបង្កើតឲ្យមានភាពស្និទ្ធស្នាលរវាង គ្នានឹងគ្នាផងដែរ។ *ដោយ សុធីរិទ្ធិ*



ថតដោយ សុធីរិទ្ធិ

## សម្តេចប៉ាប ទទួលជួបសវនការជាមួយ នឹងគណៈប្រតិភូមកពីព្រះសហគមន៍មួយនៅនីហ្សេរីយ៉ា

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ត្រូវបានវិទ្យុវ៉ាទីកង់រាយការណ៍ថា បានទទួលជួបជាមួយនឹង គណៈប្រតិភូមកពីព្រះសហគមន៍អាហៀរ៉ា នៃប្រទេសនីហ្សេរីយ៉ាកាលពីសប្តាហ៍មុន។

នៅក្នុងជំនួបនោះសម្តេចប៉ាប និងគណៈប្រតិភូព្រះសហគមន៍មកពីព្រះសហគមន៍ អាហៀរ៉ា នៃប្រទេសនីហ្សេរីយ៉ា បានពិភាក្សាអំពីកិច្ចការផ្ទៃក្នុងរបស់ព្រះសហគមន៍នៅក្នុងភូមិភាគនោះ។ ប្រភពដដែលបានរាយការណ៍ថា សម្តេចប៉ាប បានបង្ហាញនូវអារម្មណ៍ទុក្ខសោក នៅក្នុងករណីដែលគ្រីស្តនៅព្រះសហគមន៍នោះ បានបដិសេធនៅក្នុងការទទួលអភិបាលដែលត្រូវបានតែងតាំងសម្រាប់ពួកគេ។

នាឱកាសនោះ សម្តេចប៉ាប បានស្នើសុំគណៈប្រតិភូឲ្យពិចាណាឡើងវិញ នូវការតែងតាំងលោកភីធ័ អេប៉េ អុកប៉ាល-គើ ដែលត្រូវបានតែងតាំងជាអភិបាលនៃព្រះសហគមន៍នេះដោយសម្តេចប៉ាបបេណេឌិកទី១៦ កាលពីឆ្នាំ២០១២។

បន្ទាប់ពីស្តាប់ប្រសាសន៍របស់សម្តេចបប៉ា លោកកាឌីណាល់ ចន អូណាយេកាន អគ្គអភិបាលនៃព្រះសហគមន៍នោះ បានអរគុណសម្តេចប៉ាប ហើយក៏មានការស្នើសុំផ្ញើធម្មយាត្រាមួយមកទីក្រុងរ៉ូម ដើម្បីជួបសម្តេចប៉ាប ម្តងទៀតដោយសង្ឃឹមថាស្ថានការណ៍នឹងត្រូវដោះស្រាយដោយសំណើនេះត្រូវបានសម្តេចប៉ាបទទួលយក។

## អាជ្ញាធរថៃរឹបអូសគ្រឿងញៀនបានយ៉ាងសន្ធឹកសន្ធាប់

ថ្នាំញៀនជាង៤លានគ្រាប់ត្រូវបានអាជ្ញាធរថៃចាប់និងរឹបអូសបាន ក្រោយពីពួកអ្នកជួញដូរបានបោះបង់ចោលរថយន្តរបស់គេ និងរត់គេចខ្លួននៅស្រុកមួយក្នុងខេត្តឈៀងរ៉ៃ ភាគខាងជើងកាលពីយប់ថ្ងៃសុក្រសប្តាហ៍មុន។ យោងតាមកាសែតថៃ ទាហានមកពី២អង្គភាពបានស្ទាក់ឃាត់រថយន្តមួយដើម្បីឆែក តែអ្នកបើកបានឈប់ និងរត់ចោលរថយន្ត។ ក្រោយការឆែកមើលគេកឃើញបាវ១៦ នៅក្នុងរថយន្តហើយបាវមួយៗផ្ទុកថ្នាំមេតំហ្វេតាមីនសរុបទាំង១៦ បានមានចំនួន៤,២លានគ្រាប់។ ការស្ទាក់ចាប់នេះកើតឡើងក្រោយពីទទួលបានព័ត៌មានអំពីការដឹកជញ្ជូនថ្នាំញៀនមកពីព្រំដែនឡាវ។ នៅខេត្តប្រាជួបភាគខាងត្បូងឯណេះវិញជនសង្ស័យចំនួន៣នាក់ រួមជាមួយនឹងថ្នាំញៀនជិត១លានគ្រាប់ត្រូវបានកំលាំងជំនាញនៃអង្គភាពប្រឆាំងគ្រឿងញៀនធ្វើការតាមប្រមាញ់រហូតឈានដល់ការបង្ក្រាបបន្ទាប់ពីទទួលបានសេចក្តីរាយការណ៍ច្បាស់ពីកំលាំងសម្ងាត់។

នៅព្រឹកថ្ងៃទី០៩ មិថុនា ២០១៧ អង្គភាពប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋានតម្រួតប្រទេសថៃ បានធ្វើការដាក់កំលាំងដើម្បីស្ទាក់ចាប់រថយន្តពីរគ្រឿង ដែលគេសង្ស័យថាអាចមានការរត់ពន្ធនូវសារធាតុញៀនយកទៅចែកចាយតាមបណ្តាខេត្តមួយចំនួននៅភាគខាងត្បូងនៃប្រទេសថៃ និងបានរកឃើញមានថ្នាំញៀនប្រភេទយ៉ាម៉ាចំនួន៩៥៦ ដុំ ស្មើនឹង៩១២.០០០គ្រាប់។

ក្រៅពីគ្រឿងញៀនទាំងនោះ នៅពេលនេះអាជ្ញាធរថៃបានរឹបអូសគ្រឿងញៀនរាប់សិបលានគ្រាប់ទៀត ហើយក៏កំពុងតែស្រាវជ្រាវករណីជួញដូរដ៏ធំមួយផ្សេងទៀត ដែលបាននាំឲ្យទាក់ទងនឹងក្រុមអ្នកជួញដូរដ៏ធំមួយ ដោយនៅក្នុងនោះតារាថៃមួយចំនួនក៏កំពុងតែជាប់សង្ស័យផងដែរ។

## សម្តេចប៉ាប សួរសុខទុក្ខលោកប្រធានាធិបតីអ៊ីតាលី

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ត្រូវបានវិទ្យុវ៉ាទីកង់រាយការណ៍ថា បានអញ្ជើញជួបសាកសួរសុខទុក្ខ លោកស៊ែជីអូ ម៉ាតារ៉េឡា ប្រធានាធិបតីនៃប្រទេសអ៊ីតាលី នៅវិមានម៉ាតារ៉េឡា តំបន់និវេសនដ្ឋាន ឃ្វីរីណាល់ នៅក្នុងទីក្រុងរ៉ូម។ ប្រភពដដែលបានរាយការណ៍ថា ជំនួបសាកសួរសុខទុក្ខនេះ ត្រូវបានគេដឹងថា បានធ្វើឡើងកាលពីថ្ងៃទី១១ មិថុនា ២០១៧ ដោយនៅក្នុងជំនួបនោះ មេដឹកនាំទាំងពីរបានពិភាក្សាគ្នា អំពីព្រះសហគមន៍នៅក្នុងប្រទេសអ៊ីតាលី ដោយផ្សារភ្ជាប់ទៅនឹងព្រលឹងរបស់ប្រទេស។

គួររំឭកថាសម្តេចប៉ាបបានទៅទស្សនកិច្ចនៅនិវេសនដ្ឋាន ឃ្វីរីណាល់ កាលពីឆ្នាំ២០១៣ នៅក្នុងអំឡុងពេលដែលប្រធានាធិបតីនៃប្រទេសអ៊ីតាលីពេលនោះ គឺលោកចចជីអូ ណាប៉ូលីតាណូ ប៉ុន្តែនៅក្នុងអណត្តិរបស់លោកប្រធានាធិបតីថ្មីនេះ គឺសម្តេចប៉ាបធ្លាប់ជួប សន្ទនាតាមទូរស័ព្ទនៅពេលដែលលោកត្រូវបានជ្រើសតាំងជាប្រធានាធិបតីកាលពីឆ្នាំ២០១៥។

ប្រភពដដែលបានរាយការណ៍ថា នៅក្នុងជំនួបសម្តេចប៉ាបបានលើកឡើងពីសេចក្តីសង្ឃឹមរបស់គ្រីស្តសាសនិកនៅលើពិភពលោកនិងបញ្ហាព្រមទាំងហានិភ័យផ្សេងៗ។

សម្តេចប៉ាបក៏បានថ្លែងថា អ៊ីតាលី និងអឺរ៉ុបត្រូវបានស្នើសុំឲ្យដោះស្រាយនូវបញ្ហាជាច្រើន គឺភេរវកម្មអន្តរជាតិ ដែលជាការជ្រៀតនៃបាតុភូតដ៏អាក្រក់សម្រាប់អឺរ៉ុប ដែលនាំឲ្យមានអតុល្យភាពនៃសេដ្ឋកិច្ច និងសង្គមនៅតំបន់ជាច្រើន។

## សម្តេចប៉ាប អាហាររូបករណ៍មិនមែនដើម្បីតែឥស្សរ ភាពមួយមុខនោះទេ

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃសុក្រ បានសម្ពោធការិយាល័យវ៉ាទីកង់ថ្មីមួយដែលមានតួនាទីជាមូលនិធិសម្រាប់ទទួលបន្ទុកចំពោះអាហារូបករណ៍នៅក្នុងព្រះសហគមន៍។

វិទ្យុវ៉ាទីកង់បានរាយការណ៍ថា ការិយាល័យថ្មីនេះ គឺមានតួនាទីនៅក្នុងការជំរុញ និងផ្សព្វផ្សាយនូវការអប់រំអន្តរជំនឿ សិល្បៈ និងកីឡា ដើម្បីបង្កើតនូវវប្បធម៌នៃការតស៊ូដើម្បីសន្តិភាព។ ប្រភពដដែលបានរាយការណ៍ថា នាឱកាសនោះ សម្តេចប៉ាបបានផ្សារភ្ជាប់យុវជនមួយក្រុមមកពីប្រទេសចំនួន៩ ដែលមានដូចជា អ៊ីតាលី កូឡុំប៊ី ហៃទី ប៉ារ៉ាហ្គាយ អាហ្សង់ទីន ប្រេស៊ីល ម៉ិកស៊ិក អេស្ប៉ាញ និងសហភាពអារ៉ាប់ អេមីរ៉ាតទៅនឹងគ្រាប់ពូកថ្មីនៃសន្តិភាព។

សម្តេចប៉ាបបានថ្លែងថា ឥស្សរភាព គឺជាគ្រោះថ្នាក់មួយ បើយើងមិនគិតជាពិសេសសម្រាប់យុវជនដែលទទួលការអប់រំពីព្រះសហគមន៍។ ដោយបានលើកឡើងថា ការគាំទ្រហិរញ្ញវត្ថុ ដើម្បីការអប់រំនៅក្នុងកន្លែងខ្លះកំពុងតែបង្កើតនូវឥស្សរភាព ដោយសារតែគេអាចទទួលការចំណាយសម្រាប់ការអប់រំ ប៉ុន្តែសូមកុំភ្លេចថា នៅលើពិភពលោកមានកុមារា និងកុមារីជាច្រើនដែលមិនមានឱកាសទទួលបានការអប់រំ។ ដូច្នេះត្រូវយល់ថា អាហារូបករណ៍គឺជានិមិត្តរូបនៃក្តីស្រលាញ់ដោយចិត្តបេះដូង ហើយទាំងអស់គ្នាគួររួមគ្នា ដើម្បីចែករំលែកការអប់រំមិនមែនដើម្បីតែឥស្សរភាពបុគ្គលនោះទេ ។

## សម្តេចប៉ាបជួបជាមួយនឹងក្រុមនារីដែលកំពុងបម្រើកិច្ចការសន្ទនាអន្តរសាសនា

វិទ្យុវ៉ាទីកង់បានរាយកាណ៍ថា កាលពីសប្តាហ៍មុននេះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានទទួលជួបនឹងបណ្តាមេដឹកនាំស្ត្រី ដែលកំពុងតែជួបជុំគ្នានៅក្នុងទីក្រុងរ៉ូម ដើម្បីពិភាក្សាមួយ ក្រោមការរៀបចំដោយក្រុមប្រឹក្សាទទួលខុសត្រូវកិច្ចការសន្ទនាអន្តរសាសនា។

ប្រភពដដែលបានបន្តថា ក្រុមមេដឹកនាំស្ត្រីដែលបានជួបសម្តេចប៉ាបកាលពីថ្ងៃសុក្រសប្តាហ៍មុននោះ គឺសុទ្ធតែជា នារី ដែលកំពុងតែបានរួមវិភាគទានជាច្រើននៅក្នុងកិច្ចការទទួលខុសត្រូវទំនាក់ទំនងអន្តរជំនឿ។ នៅក្នុងឱកាសនោះ សម្តេចប៉ាបបានវាយតម្លៃខ្ពស់ចំពោះកិច្ចការដែលក្រុមស្ត្រីបានកំពុងតែប្រឈម ទោះបីជាពួកគេកំពុងតែបម្រើនូវកិច្ចការមួយដ៏ថ្លៃថ្នូរ។

សម្តេចប៉ាបបានថ្លែងថា នោះគឺជាកិច្ចការប្រកបដោយកិត្តិយស ប៉ុន្តែជាទូទៅស្ត្រីអាច ប្រឈមមុខនឹងការតំរាមកំហែងដោយអំពីហិង្សា និងការស្អប់ខ្ពើមប្រកបដោយទឹកភ្នែក ពីសង្គម និងគ្រួសារខ្លះផងដែរ ប៉ុន្តែគឺត្រូវតែជម្នះ។

សម្តេចប៉ាបបានថ្លែងថា ទោះបីជាត្រូវប្រឈមនឹងបញ្ហាសាកលជាច្រើន ប៉ុន្តែនេះគឺជាសេចក្តីត្រូវការដើម្បីទទួលស្គាល់អំពីសក្តានុពលនិងលទ្ធភាពរបស់ស្ត្រីដើម្បីផ្តល់នូវតម្លៃ នៃការឯកភាពចំពោះស្ត្រីនៅក្នុងការជួយការរីកចម្រើនរបស់សង្គម និងគ្រួសារ ។

## ជម្លោះនៅតំបន់ភាគខាងត្បូងថៃអាចត្រូវបានគេងយកចំណេញដោយក្រុមអាយស៊ីស

ក្រុមអ្នកវិភាគនិយាយថា ជម្លោះប្រដាប់អាវុធនៅទីក្រុងម៉ារ៉ាវី ប្រទេសហ្វីលីពីន អាចធ្វើជាការរំលឹកដាស់តឿនមួយសម្រាប់ក្រុមអាជ្ញាធរថៃឱ្យដោះស្រាយការបះបោរនៅតំបន់ភាគខាងត្បូងថៃនេះ ស្របពេលដែលភាពតានតឹងនេះអាចបើកទ្វារសម្រាប់ក្រុមភេរវកម្មអាយស៊ីស ដែលជាញឹកញយកេងយកចំណេញពីជម្លោះដែលជាប់ពាក់ព័ន្ធអ៊ីស្លាម។

កាលពីសប្តាហ៍មុន ថៃបានចាប់ផ្តើមដាក់ពង្រាយកងទ័ពឱ្យល្បាត២៤ម៉ោងនៅខេត្តណារ៉ាធីវ៉ាត់ និងខេត្តយ៉ាឡា ដែលនៅជាប់ព្រំដែនជាមួយម៉ាឡេស៊ី បន្ទាប់ពីមានព័ត៌មានអំពីការចាប់ខ្លួនក្រុមសមាជិកនៃក្រុមអាយស៊ីសដែលមានទំនាក់ទំនាក់ទំនងជាមួយក្រុមជនសកម្មប្រយុទ្ធម៉ាឡេស៊ី ដែលបានជួញដូរអាវុធឆ្លងកាត់ព្រំដែននោះ។ ទោះយ៉ាងនេះក្តី រដ្ឋាភិបាលថៃមានការជឿជាក់ថា វាជាការលំបាកសម្រាប់ក្រុមអាយស៊ីសនៅអ៊ីរ៉ាក់និង ក្រុមជនសកម្មប្រយុទ្ធអាយស៊ីសនៅស៊ីរី ក្នុងការសោបព្រោះមនោគមនិយមរបស់ពួកគេនៅតំបន់ភាគខាងត្បូងនេះ ដែលមានជនអ៊ីស្លាមម៉ាឡេស៊ីរស់នៅច្រើននេះ។

ក្រុមអ្នកវិភាគនិយាយថា ក្រុមឧទ្ទាមអ៊ីស្លាមភាគច្រើន នៅតំបន់ភាគខាងត្បូងថៃនេះក៏បានបញ្ជាក់យ៉ាងច្បាស់រួចហើយថា ក្រុមអាយស៊ីសមិនត្រូវបានទទួលស្វាគមន៍នៅតំបន់នេះទេ។

# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអន្តរជាតិនៅផ្សារតូចថ្ងៃទី០៤ មិថុនា ២០១៧



អត្ថបទទី១ ៖ កក ២, ១-១១
អត្ថបទទី២ ៖ ១ករ ១២, ៣ខ-៧. ១២-១៣
ដំណឹងល្អ ៖ យហ ២០, ១៩-២៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងមានអំណរសប្បាយ យើងជួបជុំគ្នាជាមហាគ្រួសាររបស់ព្រះគ្រីស្ត នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅពេលយើងស្តាប់ចម្រៀង ស្តាប់អត្ថបទគម្ពីរភាសាផ្សេងៗគ្នា នាំឲ្យយើងនឹកឃើញដល់ក្រុមគ្រីស្តទូតពីដើម ដែលនិយាយភាសាផ្សេងៗគ្នា។ ខ្ញុំសូមស្វាគមន៍លោកឪពុក និងបងប្អូនទាំងអស់ ដែលមកពីសហគមន៍ផ្សេងៗមាន បារាំង កូរ៉េ អង់គ្លេស...ជាដើម។

មុនព្រះយេស៊ូយាងឡើងស្ថានបរមសុខ ព្រះអង្គមានព្រះបន្ទូលបីដ៏សំខាន់ដល់ក្រុមគ្រីស្តទូត "សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត ដូចព្រះបិតាដែលបានចាត់ខ្ញុំឲ្យមកយ៉ាងណា ខ្ញុំឲ្យអ្នករាល់គ្នាទៅយ៉ាងនោះដែរ ចូរទទួលព្រះវិញ្ញាណ"។ យើងអាចនិយាយថា ព្រះបន្ទូលទាំងបីនេះ គឺជាលក្ខខណ្ឌដែលព្រះយេស៊ូទុកឲ្យក្រុមគ្រីស្តទូត ដែលជាអ្នកបន្តបេសកកម្មពីព្រះអង្គជាបេសកកម្មដែលព្រះអង្គបានចាប់ផ្តើម។ ព្រះយេស៊ូបានប្រទានសេចក្តីសុខសាន្តនេះឲ្យគេ ដោយសារសេចក្តីសុខសាន្តនេះមកពីព្រះជាម្ចាស់ ជាមូលដ្ឋានគ្រឹះនៃគ្រប់បេសកកម្មក្នុងជីវិតរបស់គេ និងរបស់យើងដែរ។ សព្វថ្ងៃប្រសិនបើក្នុងដួងចិត្តរបស់យើងឥតមានសេចក្តីសុខសាន្ត នោះយើងមិនអាចកសាងសេចក្តីសុខសាន្តនៅក្នុងពិភពលោកបានទេ ហើយបើពិភពលោកឥតមានសេចក្តីសុខសាន្តទេ នោះពិភពលោកយើងក៏មិនអាចអភិវឌ្ឍបានដែរ។ ប្រសិនបើយើងឥតមានសេចក្តីសុខសាន្តរវាងគ្នានឹងគ្នានៅក្នុងព្រះសហគមន៍ នោះព្រះសហគមន៍យើងក៏មិនអាចមានជីវិតបានដែរ។

ពេលនេះប្រសិនបើយើងត្រឡប់មើលទៅថ្ងៃដំបូងដែលព្រះជាម្ចាស់បង្កើតពិភពលោក នោះយើងឃើញថា កាលនោះពិភពលោកមានសេចក្តីសុខសាន្ត និងសុខដុមរមនារវាងគ្នានឹងគ្នាខ្លាំងណាស់។ ប៉ុន្តែបន្ទាប់មក មានអាដាំនិងអេវ៉ាដែលចាប់ផ្តើមមានចិត្តលោភលន់។ អាដាំនិងអេវ៉ា ជាតំណាងឲ្យមនុស្សជាតិ បានចាប់ផ្តើមតាំងខ្លួនស្មើនឹងព្រះជាម្ចាស់ ហើយមនុស្សបានខិតខំសាងសង់កំពូលប្រាសាទបាបែលដើម្បីបង្ហាញថា ខ្លួនមានអំណាចលើសព្រះជាម្ចាស់ ដែលនៅពេលនោះព្រះជាម្ចាស់បានបំបែកគេ ដើម្បីបង្កើតសេចក្តីសុខសាន្តសាជាថ្មី។ ក្រោយមកមានទឹកជំនន់លិចពិភពលោកទាំងមូល និងបន្ទាប់ពីទឹកបានស្រកចុះ មានសញ្ញាមួយទៀតគឺព្រាបសដែលហើរចេញពីសំពៅលោកណូអេ បានត្រឡប់មកវិញដើម្បីបង្ហាញថា សេចក្តីសុខសាន្តបានមកវិញហើយ។

ដូច្នេះតាំងពីដើមរៀងមក ព្រះជាម្ចាស់បានបង្កើតសេចក្តីសុខសាន្តសម្រាប់មនុស្សយើង ជាអ្វីដែលពិភពលោករបស់យើងត្រូវការយ៉ាងខ្លាំង។ នៅក្នុងពិភពលោករបស់យើងសព្វថ្ងៃ ប្រទេសមហាអំណាចកំពុងតែទាស់គំនិតគ្នា ក្នុងការការពារពិភពលោក ការពារធម្មជាតិ និងការពារអ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានប្រទានឲ្យយើងទុកជាលំនៅដ្ឋានរួម។ កាលពីប៉ុន្មានឆ្នាំកន្លងទៅ មេដឹកនាំប្រទេសធំៗក្នុងពិភពលោក បានចុះហត្ថលេខាឯកភាពគ្នាលើការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ តែឥឡូវនេះ គេបែកបាក់គ្នាលើគោលការណ៍នេះ។ ព្រឹកមិញនៅប្រទេសអង់គ្លេសមានភេរវកម្មកើតឡើង... ទាំងអស់នេះបង្ហាញថា ដោយសារតែទំនាក់ទំនងគ្នារបស់មនុស្សយើងខ្វះសេចក្តីសុខសាន្ត ដូច្នេះយើងមិនខ្វះទេការស្អប់គ្នា ការនិយាយដើមគ្នា ការបង្ករឿងដាក់គ្នាទាំងនៅក្នុងសង្គម និងទាំងនៅក្នុងព្រះសហគមន៍ដែរ។

ប៉ុន្តែថ្ងៃនេះ ព្រះយេស៊ូមានព្រះបន្ទូលយ៉ាងច្បាស់មកយើងថា "សូមសេចក្តីសុខសាន្តគង់នៅជាមួយបងប្អូន" ដែលមានន័យថា សូមឲ្យបងប្អូនទទួលយកសេចក្តីសេចក្តីសុខសាន្តទុកក្នុងខ្លួន ដើម្បីកសាងជីវិតរបស់ខ្លួនផ្ទាល់ ដើម្បីកសាងទំនាក់ទំនងល្អរវាងគ្នានឹងគ្នា ដើម្បីកសាងព្រះសហគមន៍ និងពិភពលោករបស់យើង។ ដូច្នេះសូមឲ្យយើងយកចិត្តទុកដាក់រក្សាសេចក្តីសុខសាន្តដែលព្រះជាម្ចាស់បានប្រទានឲ្យយើង ដ្បិតមានតែសេចក្តីសុខសាន្តនេះទេ ដែលណែនាំឲ្យជីវិតរបស់យើងរីកចម្រើន និងឲ្យពិភពលោករបស់យើងអភិវឌ្ឍយ៉ាងពិតប្រាកដ។ នៅពេលយើងពោរពេញដោយ សេចក្តីសុខសាន្ត ពេលនោះយើងនឹងអាចទទួលព្រះបន្ទូលមួយថែមទៀតគឺ "ដូចព្រះបិតាបានចាត់ខ្ញុំឲ្យមកយ៉ាងណាខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅយ៉ាងនោះដែរ" ដែលមានន័យថាព្រះអង្គចាត់យើងឲ្យទៅបំពេញបេសកកម្ម។ ជាពិសេសព្រះបន្ទូលនេះ គឺសម្រាប់បងប្អូនដែលនឹងទទួលអគ្គសញ្ញា លាបថ្ងាសនៅពេលនេះ គឺព្រះយេស៊ូចាត់បងប្អូនឲ្យទៅប្រកាសដំណឹងល្អដូចព្រះអង្គដែរ។ ព្រះយេស៊ូបានជ្រើសរើសយើងទាំងអស់គ្នា ឲ្យទទួលបេសកកម្មដូចព្រះអង្គបានទទួលពីព្រះបិតា។ យើងបន្តបេសកកម្មរបស់ព្រះយេស៊ូដោយយើងបន្តប្រកាសដំណឹងល្អនៅលើផែនដីនេះតាមការរស់នៅរបស់យើង។ បងប្អូនត្រូវគិតអំពីរបៀបដែលយើងត្រូវប្រកាសដំណឹងល្អ ដោយកុំគិតស្មានថាយើងត្រូវប្រកាសតាមរបៀបដ៏អស្ចារ្យ តាមពិតគឺយើងប្រកាសតាមរបៀបធម្មតាក្នុងជីវិតប្រចាំថ្ងៃរបស់យើង ដោយឲ្យយើងចេះបង្ហាញសេចក្តីស្រឡាញ់នៅក្នុងគ្រួសារ នៅក្នុងសាលា នៅកន្លែងធ្វើការ...។ ដោយឲ្យយើងចេះបម្រើគ្នាទៅវិញទៅមក ដូចព្រះយេស៊ូប្រទានសញ្ញាចុងក្រោយមុនពេលព្រះអង្គសោយទិវង្គត គឺព្រះអង្គបានលាងជើងក្រុមសាវ័ក ដោយមានព្រះបន្ទូលថា "សូមបម្រើគ្នាទៅវិញទៅមក"។ សេចក្តីស្រឡាញ់ពិតប្រាកដ គឺនៅពេលណាយើងបម្រើគ្នាទៅវិញទៅមក។ ចុងក្រោយដោយឲ្យយើងយកចិត្តទុកដាក់លើកលែងទោសគ្នាទៅវិញទៅមក គឺលើកលែងទោស យ៉ាងជ្រៅពីក្នុងដួងចិត្តរបស់យើង ដោយទទួលការលើកលែងទោសពីគេ និងយកចិត្តទុកដាក់លើកលែងទោសឲ្យគេដែរ។ ទាំងអស់នេះ គឺជាការបំពេញបេសកកម្មដ៏អស្ចារ្យ ដែលយើងបានទទួលពីព្រះយេស៊ូ ដើម្បីប្រកាសដំណឹងល្អ អំពីព្រះរាជ្យព្រះជាម្ចាស់តាមរយៈជីវិតប្រចាំថ្ងៃរបស់យើង។

ព្រះយេស៊ូទ្រង់ឈ្វេងយល់ថា មនុស្សយើងមិនមានកម្លាំងល្មមដើម្បីធ្វើកិច្ចការទាំងនេះទេ ហេតុដូចនេះហើយ បានជាព្រះអង្គមានព្រះបន្ទូលថា "ចូរទទួលព្រះវិញ្ញាណ" ដើម្បីទទួលកម្លាំងពីព្រះអង្គ។ ព្រះយេស៊ូមិនទុកឲ្យយើងឯកាដោយពឹងលើកម្លាំងខ្លួនឯងផ្ទាល់ ដើម្បីស្រឡាញ់ ដើម្បីបម្រើ ដើម្បីលើកលែងទោស ដើម្បីធ្វើជាគំរូដ៏វិសុទ្ធដល់គេនោះទេ តែព្រះអង្គបានប្រទានព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីជួយយើង។ ព្រះវិញ្ញាណដ៏វិសុទ្ធដែលព្រះយេស៊ូប្រទានឲ្យយើង ជាព្រះវិញ្ញាណដ៏វិសុទ្ធដែលណែនាំយើងឲ្យទៅជាឆ្លុងមួយ ដូចព្រះបិតា ព្រះបុត្រា ជាឆ្លុងតែមួយ ដើម្បីឲ្យព្រះសហគមន៍របស់ យើងទៅជាក្រុមគ្រួសារតែមួយ។ ថ្ងៃនេះនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ យើងទទួលសេចក្តីសុខសាន្ត សម្រាប់ព្រះសហគមន៍របស់យើង ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាគ្រួសារមួយ ដែលយើងសប្បាយចិត្តពេលយើងជួបជុំគ្នា ដែលយើងសប្បាយចិត្តពេលយើងអធិដ្ឋានជាមួយគ្នា ដែលយើងសប្បាយចិត្តដ្បិតយើងជាបងប្អូនបង្កើតនឹងគ្នា។

ឆ្នាំនេះនៅភូមិភាគភ្នំពេញ យើងមានបេក្ខជន១៥០នាក់បានទទួលអគ្គសញ្ញាជ្រមុជទឹក ដែលមានទាំងលោកយាយចាស់ៗ មានទាំងគ្រូបង្រៀន មានទាំងប្រជាជនធម្មតា មានទាំងកូនង៉ែត មានទាំងយុវជន។ ពួកគេបានទទួលព្រះបន្ទូលទុកនៅក្នុងជីវិតរបស់គេ គេបានរកឃើញគ្រួសារមួយ ដែលចេះស្រឡាញ់គ្នាទៅវិញទៅមក ដែលចេះគោរពគ្នាទៅវិញទៅមក ដែលចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក។ គ្រួសារដែលចេះស្រឡាញ់គ្នាទៅវិញទៅមក គឺជាគ្រួសារដែលចេះទទួលបងប្អូនជានិច្ច ពេលមានបងប្អូនខ្លះវង្វេងផ្លូវ ពេលមានបងប្អូនខ្លះទៅឆ្ងាយពីព្រះយេស៊ូទាំងមិនដឹងខ្លួន ប៉ុន្តែឪពុកម្តាយគឺជាព្រះសហគមន៍នៅតែទទួលស្វាគមន៍គេជានិច្ច ទាំងលើកលែងទោសឲ្យគេផង។ យើងទទួលអំណាចដើម្បីលើកលែងទោសឲ្យគេ ដូចយើងបានស្តាប់នៅថ្ងៃនេះថា "ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងមានសិទ្ធិលើកលែងទោសឲ្យគេ"។ យើងមានការពិសោធអំពីការលើកលែងទោសនេះ ដោយដឹងថាយើងមានសមត្ថភាពលើកលែងទោសឲ្យគេ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធផ្តល់កម្លាំងឲ្យយើង ដើម្បីឲ្យយើងបង្កើតគ្រួសារដ៏សុខសាន្តមួយនៅក្នុងព្រះសហគមន៍។

សូមព្រះវិញ្ញាណដ៏វិសុទ្ធយាងមក សណ្ឋិតលើព្រះសហគមន៍ សណ្ឋិតលើពិភពលោក លើសង្គមរបស់យើង ដើម្បីឲ្យយើងរកឃើញសេចក្តីសុខសាន្ត ឲ្យយើងបំផ្លាញការស្អប់គ្នា ការមើលងាយគ្នា ការនិយាយដើមគ្នាដែលគ្មានប្រយោជន៍។ ព្រះវិញ្ញាណដ៏វិសុទ្ធសកម្ម ប៉ុន្តែបើយើងមិនសកម្មព្រះ វិញ្ញាណដ៏វិសុទ្ធមិនអាចសកម្មបានទេ។ ព្រះវិញ្ញាណដ៏វិសុទ្ធអាចសកម្ម ប្រសិនបើយើងជាអ្នក ទទួលខិតខំអនុវត្តពិតប្រាកដមែន ដោយបម្រើ ដោយស្រឡាញ់ ដោយលើកលែងទោស តែបើយើងដេកលក់ យើងបិទត្រចៀក បេះដូង ភ្នែក... នោះព្រះវិញ្ញាណដ៏វិសុទ្ធមិនអាចសកម្មបានទេ។ ហេតុនេះហើយ នៅថ្ងៃនេះយើងសូមអធិដ្ឋាន សូមព្រះវិញ្ញាណដ៏វិសុទ្ធមានឥទ្ធិពលលើព្រះ សហគមន៍របស់យើង លើពិភពលោករបស់យើង ដោយដឹងថាអ្វីៗទាំងអស់ អាស្រ័យលើយើងបើកចិត្តគំនិត បើកភ្នែក បើកត្រចៀក ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធមានសកម្មភាពនៅក្នុងពិភពលោកយើង ដើម្បីឲ្យពិភពលោករបស់យើងទទួលសេចក្តីសុខសាន្ត ដូចព្រះយេស៊ូមានព្រះបន្ទូលថា "សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត"។ អាម៉ែន។

# រូបភាពសកម្មភាពរបស់ព្រះសហគមន៍



សំណាក់ធម៌ និងការបោះជំរំ យុវជននៃព្រះសហគមន៍ភូមិភាគកំពង់ចាម នៅព្រះសហគមន៍ ឃ្សឹម ខេត្តក្រចេះ





គណៈកម្មការព្រះសហគមន៍សន្ត យ៉ូសែប ផ្សារតូច ទៅទស្សនកិច្ច និងបូជនីយចរណ៍នៅភូមិភាគ ច័ន្ទបុរី



ពិធីតាំងព្រះកាយព្រះគ្រីស្ត នៅព្រះសហគមន៍កាតូលិក ត្រែងត្រយឹង





បុណ្យគោរពព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត នៅព្រះសហគមន៍ កាតូលិកបាត់ដំបង។ ថតដោយ រិទ្ធិរដ្ឋ







បុណ្យគោរពព្រះកាយ នឹងព្រះលោហិតព្រះគ្រីស្ត នឹងមានប្អូនៗ ២០នាក់ ទទួលព្រះកាយព្រះគ្រីស្តលើកដំបូង នៅព្រះសហគមន៍សន្ត យ៉ូសែប (ផ្សារតូច)។ ថតដោយ លីហៀង


Radio Veritas Asia
Khmer Service
RADIO VERITAS ASIA-KHMER SERVICE

## វិទ្យុវ៉ារីតាស់អាស៊ីខេមរភាសា

### សំលេងពីព្រះសហគមន៍កាតូលិកកម្ពុជា

**✣ ផ្សាយតាមរលកធាតុអាកាស FM**

| | | |
|---|---|---|
| ភ្នំពេញ | : FM 104 Mhz | ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| បាត់ដំបង | : FM 91.0 Mhz | ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| សៀមរាប | : FM 98.75 Mhz | ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| កំពង់ធំ | : FM 102.5 Mhz | ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| កំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| ព្រះសីហនុ | : FM 100.5 Mhz | ម៉ោង ៦:០០- ៧:០០ រាល់ថ្ងៃ |
| កំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |

**✣ ផ្សាយតាមរលកធាតុអាកាសខ្លី (SW)**

ជាភាសាខ្មែររយៈពេល ៣០ នាទីរាល់ថ្ងៃពីម៉ោង ៥:០០-៥:៣០នាទីល្ងាច តាមរលកធាតុអាកាសខ្លី ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

**✣ តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង**

លោកអ្នកអាចស្តាប់កម្មវិធីវិទ្យុវ៉ារីតាស់អាស៊ីជាភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ **Smart Phone** ដែលប្រើប្រព័ន្ធ **Android** ឬប្រព័ន្ធ **IOS** ដោយគ្រាន់តែចូលទៅកាន់ **Play Store** ឬ **App Store** វាយពាក្យ **Radio Veritas Asia** រួច **Download** កម្មវិធីនោះដោយស្វែងរកប៊ូតុង **(Khmer Live Audio)** ។

Radio Veritas Asia
Khmer Live audio

ឬ តាមរយៈវេបសាយ៖ http://khmer.rveritas-asia.org